គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល
Microfinance Institution Amatak Capital Plc.

# ២០២៤

# របាយការណ៍ប្រចាំឆ្នាំ ២០២៤

www.amatakcapital.com.kh

# មាតិកា

| | |
|---|---|
| | ទំព័រ |
| ប្រវត្តិគ្រឹះស្ថាន | ៣ |
| ទស្សនៈវិស័យ | ៤ |
| បេសកកម្ម | ៤ |
| សាររបស់ប្រធានក្រុមប្រឹក្សាភិបាល | ៥-៦ |
| សាររបស់នាយកគ្រប់គ្រងទូទៅ | ៧-៨ |
| សង្ខេបប្រតិបត្តិការប្រចាំឆ្នាំ | ៩ |
| **រចនាសម្ព័ន្ធគ្រឹះស្ថាន និង លទ្ធផលការងារ** | |
| អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា | ១០ |
| រចនាសម្ព័ន្ធការងារ | ១១ |
| ភាគទុនិក | ១២ |
| ក្រុមប្រឹក្សាភិបាល | ១៣-១៥ |
| គណៈគ្រប់គ្រង | ១៦-១៨ |
| ផលិតផល និង អតិថិជន | ១៩-២៣ |
| សង្ខេបផ្នែកប្រតិបត្តិការ | ២៤-២៦ |
| សង្ខេបផ្នែកហិរញ្ញវត្ថុ | ២៧-២៩ |
| សមត្ថភាពរបស់បុគ្គលិក | ២៩-៣០ |
| **សម្រង់របាយការណ៍សវនកម្មហិរញ្ញវត្ថុ** | |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៣២-៣៥ |
| របាយការណ៍របស់សវនករឯករាជ្យ | ៣៦-៣៩ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៤០ |
| របាយការណ៍លទ្ធផលពេញលេញ | ៤១ |
| របាយការណ៍បម្រែបម្រួលមូលធន | ៤២ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៤៣-៤៤ |
| ទំនាក់ទំនង | |

## ប្រវត្តិគ្រឹះស្ថាន

ពាក្យ **អមតៈ** មានន័យថាយូរអង្វែង ឬគ្មានព្រំដែនកំណត់ ពាក្យនេះប្រើប្រាស់ជានិមិត្តសញ្ញាតំណាងឱ្យក្រុមហ៊ុន។ លើសពីនេះទៀត ពាក្យ **អមតៈ ខាប់ភីថល ភីអិលស៊ី** គឺជាការរួមបញ្ចូលគ្នានៃភាសាខ្មែរ និងភាសាអង់គ្លេសដែលតំណាងឱ្យវប្បធម៌ក្នុងការគ្រប់គ្រងស្ថាប័ន។ ស្ថាប័ននេះ បានបង្កើតឡើងដោយបងប្អូនប្រុសខ្មែរពីរនាក់គឺ **លោក តាន់ ថាបញ្ញា** និង **លោក តាន់ ថាភត្រា** ដោយពួកគាត់មានជំនឿយ៉ាងមុតមាំថានឹងរួមចំណែកដល់ការអភិវឌ្ឍសង្គម និងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា។ ដោយសារគាត់ទាំងពីរ មានដើមកំណើតនៅប្រទេសកម្ពុជា តែបានទទួលការសិក្សាតាមរយៈប្រព័ន្ធអប់រំតាមសាលាបែបជនជាតិអូស្ត្រាលីដែលអាចឱ្យពួកគាត់សម្របខ្លួនបាន និងអាចអនុវត្តចំណេះដឹង និងនាំយកការអនុវត្តប្រកបដោយប្រសិទ្ធភាពនៅលោកខាងលិចមកកាន់ទីផ្សារក្នុងស្រុក។




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០១២ ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ 2677 KH/2012 នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ បានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣ ។ នៅក្នុងដំណាក់កាលដំបូងនៃការបង្កើត ក្រុមហ៊ុនមានដើមទុនដំបូងសរុបចំនួន ៥០០,០០០ដុល្លារអាមេរិក។ ទោះជាយ៉ាង

នេះក៏ដោយ ដោយសារតែមានតម្រូវការខ្លាំងក្នុងការបម្រើសេវាកម្មរបស់អមតៈ ខាប់ភីថល ភីអិលស៊ី ភាគទុនិកបានពេញចិត្តក្នុងការដាក់ដើមទុនបន្ថែមចំនួន ១,០០០,០០០ដុល្លារ ទៀតចូលទៅក្នុងដើមទុនដែលបានចុះបញ្ជីហើយដែលនាំឱ្យមូលនិធិរបស់ភាគទុនិកមានចំនួនសរុប ១,៥០០,០០០ដុល្លារ នៅចុងឆ្នាំ២០១៣។ ការិយាល័យកណ្តាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី មានទីតាំងស្ថិតនៅអគារលេខ៥០២ C&D ផ្លូវព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នេះជាទីតាំងដំបូងដែលក្រុមហ៊ុនចាប់ផ្តើមប្រតិបត្តិការផ្តល់សេវាប្រាក់កម្ចីដល់អតិថិជនជាលក្ខណៈបុគ្គល គ្រួសារ សហគ្រាសខ្នាតតូចបំផុត និងសហគ្រាសខ្នាតមធ្យម នៅទូទាំងរាជធានីភ្នំពេញ។

## ទស្សនៈវិស័យ

ក្លាយជាដៃគូដ៏អស្ចារ្យមួយ ក្នុងការធ្វើប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង ដើម្បីភាពរីកចម្រើនរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសជាគ្រឹះស្ថានមួយដែលផ្តល់ឱកាស និងបរិយាកាសការងារល្អដល់បុគ្គលិក។



## បេសកកម្ម

ផ្តល់ជូននូវផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈសាមញ្ញច្រើនប្រភេទ តាមរយៈសេវាធនាគារដែលល្អបំផុត។

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល



សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានសភាពរឹងមាំ និងទទួលបានការរីកចម្រើនជាបន្តបន្ទាប់បើធៀបនឹងឆ្នាំ២០២៣។ សម្រាប់ឆ្នាំ២០២៤នេះ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានកំណើនប្រហែល ៦% ធៀបនឹងឆ្នាំមុនដែលមានកំណើនត្រឹម ៥,៥% ប៉ុណ្ណោះ។ កត្តាចម្បងដែលបានជំរុញកំណើននេះ រួមមានការងើបឡើងវិញនៃការនាំចេញទំនិញដែលពឹងផ្អែកសំខាន់លើកវិស័យឧស្សាហកម្មកម្មន្តសាល ការងើបឡើងវិញនៃវិស័យទេសចរណ៍ គួបផ្សំភាពរឹងមាំនៃពាណិជ្ជកម្មក្នុងស្រុក នាំឱ្យសន្ទុះនៃការងើបឡើងវិញរបស់សេដ្ឋកិច្ចក្នុងស្រុកកាន់តែមានភាពឆាប់រហ័ស។ វិស័យឧស្សាហកម្មកម្មន្តសាលនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមកំណើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាដោយក្នុងនោះមានការចូលរួមចំណែកធំៗបីដូចជា ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មស្បែកជើង និងការផលិតទំនិញសម្រាប់អ្នកធ្វើទេសចរណ៍។ វិស័យខាងលើនេះ មិនត្រឹមតែបានជួយជំរុញដល់ការរីកចម្រើននៃសេដ្ឋកិច្ចក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានជួយបង្កើតការងាររាប់លានកន្លែងជូនដល់ប្រជាពលរដ្ឋខ្មែរផងដែរ។ វិស័យកសិកម្ម មិនសូវជាមានកំណើននោះទេ ជាក់ស្តែងមានការកើនជាងឆ្នាំមុនត្រឹម 1.2 ភាគរយប៉ុណ្ណោះ។ ផ្ទុយទៅវិញ វិស័យអចលនទ្រព្យ និងការវិនិយោគអចលនទ្រព្យនៅតែមានអត្រាធ្លាក់ចុះ នេះឆ្លុះបញ្ចាំងពីវិបត្តិអចលនទ្រព្យក្នុងស្រុក រួមផ្សំនឹងភាពមិនប្រកដប្រជានៃសេដ្ឋកិច្ចសកល ដែលបណ្តាលមកពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយក្នុងចំណោមប្រទេសមហាអំណាច ។

ទោះបីជាស្ថានភាពសេដ្ឋកិច្ចពិភពលោកជួបការរអាក់រអួល និងមានបញ្ហាប្រឈមក្នុងស្រុកក៏ដោយ វិស័យហិរញ្ញវត្ថុនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រដំណើរសេដ្ឋកិច្ចកម្ពុជាឱ្យមានភាពវិជ្ជមានជានិច្ច។ វិស័យធនាគារទាំងមូល បានកើនឡើងជាង ៣ % នៅឆ្នាំ ២០២៤ ដោយសមតុល្យឥណទានឈានដល់ចំនួន ៥៩,៩ ពាន់លានដុល្លារ។ រីឯប្រាក់បញ្ញើសរុប បានកើនឡើងជាង ១៦% ដែលបានឈានដល់ចំនួន ៥៧ ពាន់លានដុល្លារ។ សម្រាប់តួលេខក្នុងវិស័យមីក្រូហិរញ្ញវត្ថុវិញ មិនមានការប្រែប្រួលខ្លាំងនោះទេ បើធៀបនឹងឆ្នាំមុនឥណទានមានកំណើនប្រហែល១,៩% ប៉ុណ្ណោះ ដែលនាំឱ្យសមតុល្យឥណទានមានចំនួនប្រហែលជាង ៦,២ ពាន់លានដុល្លារ រីឯប្រាក់បញ្ញើវិញនៅសល់ចំនួនជាង ២,៥៥ ពាន់លានដុល្លារសម្រាប់ចុងឆ្នាំ២០២៤។ មួយវិញទៀត ឥណទានមិនដំណើរការ (NPLs) មានអត្រាខ្ពស់ជាងឆ្នាំមុនបន្តិចបន្តួចដោយឆ្នាំ២០២៤ មានអត្រា ៧,៤% បើធៀបនឹងឆ្នាំ ២០២៣ ដែលមានអត្រា ៦,៧% ប៉ុណ្ណោះ។

សម្រាប់ឆ្នាំ ២០២៤ វិស័យមីក្រូហិរញ្ញវត្ថុទាំងមូល បានខិតខំពង្រឹង និងលើកស្ទួយកេរ្តិ៍ឈ្មោះវិស័យរបស់យើងឱ្យកាន់តែប្រសើរ។ គ្រប់ស្ថាប័នបានចូលរួមអនុវត្តគំនិតផ្តួចផ្តើមមួយចំនួនដែលដាក់ចេញដោយសមាគមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមមាន: ការអនុវត្តក្រមសីលធម៌សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (code of conduct) បទដ្ឋានកិច្ចសន្យាឥណទាន (Contract Standard) និងក្រមសីលធម៌សម្រាប់ការផ្តល់

ប្រាក់កម្ចីប្រកបដោយសមធម៌ (Equitable Lending)។ ការចូលរួមអនុវត្តគម្រោងខាងលើជាយុទ្ធសាស្ត្ររយៈពេលវែងដែលអាចនាំឱ្យវិស័យមីក្រូហិរញ្ញវត្ថុទាំងមូលអាចបន្តកំណើនប្រកបដោយនិរន្តរភាព។

ជាចុងក្រោយ ខ្ញុំសូមអរគុណចំពោះសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់រួមទាំង លោកនាយកគ្រប់គ្រងទូទៅ និងបុគ្គលិកទាំងអស់ដែលបានរួមចំណែកបំពេញការងារអស់រយៈពេលពេញមួយឆ្នាំកន្លងមក។ យើងសង្ឃឹមថាក្រោយពីសេដ្ឋកិច្ចពិភពលោកមានការងើបឡើងវិញ ស្ថានភាពមានការប្រសើរឡើង ស្ថាប័នបានត្រៀមខ្លួនរួចរាល់សម្រាប់ចាប់យកឱកាសនេះបាន ។ ទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់និយ័តកររបស់យើង (ធនាគារជាតិនៃកម្ពុជា) និងអ្នកពាក់ព័ន្ធផ្សេងទៀតដូចជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ចំពោះការយោគយល់ និងការគាំទ្រកន្លងមក។

លោក តាន់ ថាភត្រា

ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់នាយកគ្រប់គ្រងទូទៅ



នៅក្នុងឆ្នាំ ២០២៤ សេដ្ឋកិច្ចពិភពលោកពោរពេញទៅដោយភាពមិនប្រាកដប្រជា វិបត្តិនេះក៏បានជ្រាបចូលក្នុងវិស័យធនាគារ ដែលជាហេតុនាំឱ្យមានសម្ពាធលើកំណើននៃវិស័យហិរញ្ញវត្ថុ។ មូលហេតុចម្បងពីរដែលរាំងស្ទះសន្ទុះឥណទានមិនអាចមានកំណើនខ្ពស់ដូចឆ្នាំមុនៗ។ ទី១ ដោយតម្រូវការឥណទានមានការធ្លាក់ចុះ បណ្ដាលមកពីការងើបឡើងវិញយឺតនៃវិស័យមួយចំនួនដូចជា សំណង់ អចលនទ្រព្យ ទេសចរណ៍ និងការលក់ដុំ និងរាយ បាននាំឱ្យមានការកាត់បន្ថយតម្រូវការប្រាក់កម្ចី។ ទី២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកាន់តែមានភាពប្រុងប្រយ័ត្នខ្ពស់ចំពោះការបញ្ចេញឥណទាន ចំពេលមានភាពមិនប្រាកដប្រជាខ្លាំងនៃសេដ្ឋកិច្ចពិភពលោក និងការធ្លាក់ចុះនូវគុណភាពឥណទាន។ ជាក់ស្ដែង ឥណទានមិនដំណើរការសម្រាប់វិស័យហិរញ្ញវត្ថុបានកើនឡើងដល់ ៧,៤% បើធៀបនឹងឆ្នាំមុនដែលមានអត្រាត្រឹម ៦,៧%។ ការិយាល័យគ្រប់គ្រងហានិភ័យរបស់យើងបាននឹងកំពុងធ្វើការយ៉ាងសកម្មដើម្បីដោះស្រាយរាល់ប្រាក់កម្ចីដែលខកខានមិនបានសងទាន់ពេលវេលាកន្លងមក។ លទ្ធផលសម្រាប់ឆ្នាំ ២០២៤ បានបង្ហាញថាឥណទានមិនដំណើរការរបស់ស្ថាប័នមានប្រមាណ ៥,៧៤% ដែលអត្រាទាបជាងតួលេខមធ្យមនៃវិស័យហិរញ្ញវត្ថុ។ មួយវិញទៀត គ្រឹះស្ថានអមតៈនៅតែខិតខំរក្សាអត្រាឥណទានជាប្រាក់រៀលមិនឱ្យធ្លាក់ទោះក្នុងកាលៈទេសៈណាក៏ដោយ។ សម្រាប់ចុងឆ្នាំ២០២៤ ឥណទានជាប្រាក់រៀល មានអត្រាប្រហែល ១២,១៦% នៃសមតុល្យឥណទានសរុប។

របាយការណ៍លទ្ធផលហិរញ្ញវត្ថុរបស់គ្រឹះស្ថាន អមតៈ ខាប់ភីថល ភីអិលស៊ី សម្រាប់ឆ្នាំ ២០២៤ មានដូចខាងក្រោមនេះ៖ សមតុល្យឥណទានសរុបទទួលបានចំនួន ៤,៣១៩,០៥៥ ដុល្លារអាមេរិក ដែលមានអតិថិជនសរុបចំនួន ២,០៧៦នាក់ ដែលក្នុងនោះឥណទានផ្ដល់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងឥណទានម៉ូតូមានសមតុល្យចំនួន ជាង ៦៤៦,៥៩៨ដុល្លារ ប្រៀបនឹងឆ្នាំ២០២៣ ដែលមានចំនួនដល់ ៨៨៦,០០១ ដុល្លារអាមេរិក។ ក្នុងឆ្នាំ ២០២៤ ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងឥណទានម៉ូតូមានអត្រាជាង ១៥% នៃសមតុល្យឥណទានសរុប។ ផលិតផលមួយទៀតដែលទទួលបានការគាំទ្រយ៉ាងខ្លាំងពីអតិថិជន ហើយជាផលិតផលដែលស្ថាប័នបានច្នៃប្រឌិតដាក់ឱ្យប្រើប្រាស់លើទីផ្សារនោះ គឺឥណទានកាតគ្រី។ ជាពិសេសអតិថិជនដែលមិនមានអចលនទ្រព្យសម្រាប់ដាក់តម្កល់។ ចំនួនឥណទានកាតគ្រី មានការកើនឡើងបន្តិចបន្តួចដែលមានសមតុល្យជាង ៦៩៦,១៩៥ ដុល្លារ ធៀបនឹងឆ្នាំមុនដែលមានចំនួនជាង ៦០៦,០៣៩ដុល្លារ។ ដូចគ្នានេះដែរ គុណភាពឥណទានរបស់ អមតៈ ខាប់ភីថល ដែលវាស់ស្ទង់ដោយឥណទានដែលលើសកាលកំណត់ច្រើនជាង ៣០ ថ្ងៃ មានអត្រាជាង ៥,៧៤% និងអនុបាតប្រសិទ្ធភាពប្រតិបត្តិការគឺ ៥០,២៧%។ ជារួមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី ទទួលខាតបង់ចំនួន ១៥៨,៥៥២ ដុល្លារអាមេរិក។ តួ

លេខប្រាក់ចំណេញប្រែអវិជ្ជមាន គឺដោយសារតែការបញ្ចេញប្រាក់កម្ចីមិនមានការរីកចម្រើនទៅតាមផែនការដែលថ្នាក់គ្រប់គ្រងបានដាក់ជូននាដើមឆ្នាំ នេះបណ្តាលឱ្យសមតុល្យឥណទានធ្លាក់ចុះយ៉ាងខ្លាំងបើប្រៀបធៀបទៅនឹងឆ្នាំមុន។ ការចំណាយប្រតិបត្តិការរបស់ស្ថាប័នបានកើនឡើងជាលំដាប់ លើសពីនេះទៀតគុណភាពឥណទានក៏មានភាពកាន់តែយ៉ាប់យ៉ឺនជាងមុន ដែលតម្រូវឱ្យស្ថាប័នធ្វើការលុបចេញនូវឥណទានមិនដំណើរការមួយចំនួនធំដែលមានចំនួនដល់ ៤៨,៣៥៥ ដុល្លារ។ ប្រាក់ចំណូលសរុបរបស់ស្ថាប័នបានធ្លាក់ចុះប្រហែល ៦,៧% ដោយសាខាទាំង៣ របស់យើងទទួលបានលទ្ធផលទាបជាងការរំពឹងទុក។

ទៅថ្ងៃអនាគត គោលដៅរួមរបស់យើង គឺបង្កើនសមតុល្យឥណទានសរុបឱ្យដល់ ៥,៧ លានដុល្លារនៅចុងឆ្នាំក្រោយនេះ។ ដោយគុណភាពនៃឥណទាន (NPL) ស្ថិតនៅកម្រិតខ្ពស់រហូតដល់ ៥,៧% ដូច្នេះថ្នាក់ដឹកនាំបានសង្កត់ធ្ងន់ធ្វើយ៉ាងណាកុំឱ្យអត្រានេះឡើងលើស ៤,៥% នៅចុងឆ្នាំ ២០២៥។ ថ្នាក់ដឹកជាន់ខ្ពស់ត្រូវស្វែងរកយុទ្ធសាស្ត្រថ្មីៗ ជាពិសេសការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល និងផ្សាយពាណិជ្ជកម្មតាមបណ្តាញសង្គមដើម្បីទាក់ទាញអតិថិជនថ្មី។ ជាងនេះទៅទៀត នាយកដ្ឋានទីផ្សារត្រូវខិតខំប្រឹងប្រែងយ៉ាងសកម្មដើម្បីផ្សារភ្ជាប់ទំនាក់ទំនងល្អជាមួយភ្នាក់ងារខាងក្រៅ និងភ្នាក់ងារចែកចាយម៉ូតូរបស់យើង ដើម្បីជំរុញផលិតផលឥណទានម៉ូតូដែលទើបបានធ្វើការកែសម្រួល ឱ្យកាន់តែមានប្រជាប្រិយភាពជាងមុន។

ជាចុងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលរបស់យើងទាំងអស់ដែលបានគាំទ្រយ៉ាងពេញទំហឹងក្នុងកំឡុងពេលមួយឆ្នាំកន្លងមកនេះ។ បុគ្គលិករបស់យើងបានធ្វើការងារប្រកបដោយវិជ្ជាជីវៈខ្ពស់ ហើយបានបង្ហាញពីភាពស្មោះត្រង់ជាមួយស្ថាប័នយើងផងដែរ។ ខ្ញុំបាទសង្ឃឹមថាបុគ្គលិកគ្រប់ជាន់ថ្នាក់នឹងពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដើម្បីសម្រេចបានផែនការឆ្នាំថ្មី។

នាយកគ្រប់គ្រងទូទៅ

លោក តាន់ ថាបញ្ញា

# សង្ខេបប្រតិបត្តិការប្រចាំឆ្នាំ ២០២៤

**ប្រាក់ចំណេញសុទ្ធ**
**-១៥៨,៥២២ ដុល្លារអាមេរិក**
ក្នុងឆ្នាំ ២០២៤ អមតៈ ទទួលការខាតបង់ចំនួនជាង ១៥៨,៥២២ ដុល្លារ តួលេខនេះមានការប្រែប្រួលយ៉ាងខ្លាំង។ ស្ថាប័នទទួលបានលទ្ធផលមិនល្អពេញមួយឆ្នាំ។

**ផលលើទ្រព្យសកម្ម**
**-៣,៦១%**
តម្លៃទ្រព្យសកម្មក្នុង ១០០ ដុល្លារអាមេរិក គឺខាតបង់អស់ ៣,៦១ ដុល្លារអាមេរិក។ តួលេខនេះតំណាងប្រសិទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួន។

**ផលលើមូលធន**
**-៧,៣៨%**
តម្លៃមូលធនក្នុង ១០០ ដុល្លារអាមេរិក គឺភាគទុនិករបស់អមតៈខាតអស់ចំនួន ៧,៣៨ ដុល្លារ។ ស្ថាប័នបានប្តេជ្ញាថានឹងខិតខំធ្វើយ៉ាងណាកែតួលេខនេះ ឱ្យមកវិជ្ជមានវិញឱ្យបាន។

---

**មានអតិថិជនចំនួន**
**២,០៧៦នាក់**
នៅឆ្នាំ២០២៤ គ្រួសារជាងពីរពាន់នាក់បានទទួលអត្ថប្រយោជន៍ពីប្រាក់កម្ចី ដែលផ្តល់ដោយ អមតៈ ខាប់ភីថល ភីអិលស៊ី។

**អនុបាតសាធនភាព**
**៥០,២៧%**
អនុបាតសាធនភាពរបស់ស្ថាប័នស្ថិតក្នុងកម្រិតល្អនៅឡើយ ៥០,២៧% ។ សមត្ថភាពក្នុងការបំពេញកាតព្វកិច្ចបំណុលរយៈពេលវែងនៅមិនមានបញ្ហា ។

**សមតុល្យឥណទានសរុបចំនួន**
**៤,៣១៩,០៥៥ ដុល្លារ**
សមតុល្យឥណទានសរុបចំនួនជាង ៤,៣ លានដុល្លារ អាមេរិក តួលេខនេះគឺទាបជាងនឹងឆ្នាំមុនបន្តិចបន្តួច។ វិបត្តិសេដ្ឋកិច្ចបណ្តាលឱ្យឥណទានមិនមានការកើនឡើង។

---

**អត្រាឥណទានដែលមានហានិភ័យ គឺចំនួន ៥,៧៤%**
ឥណទានហួសកាលកំណត់លើស ៣០ ថ្ងៃ កើនដល់ ៥,៧៤% តួលេខនេះគឺទាបជាងតួលេខក្នុងវិស័យ។ ស្ថាប័នសង្ឃឹមថានឹងអាចកាត់បន្ថយអត្រានេះ នាថ្ងៃអនាគត។

**ឥណទានដែលលុបចេញមានចំនួន ៤៨,៣៥៥.២៩ ដុល្លារ**
ក្នុងឆ្នាំ ២០២៤ គ្រឹះស្ថានបានលុបចោលឥណទានចំនួន ៤៨,៣៥៥.២៩ ដុល្លារ ពីបញ្ជី។

**សរុបទ្រព្យសកម្មមានចំនួន ៤,៣៩៦,៩៥៩ ដុល្លារ**
សរុបទ្រព្យសកម្មនៅចុងឆ្នាំ ២០២៤ មានចំនួនជាង ៤,៤ លានដុល្លារអាមេរិក តួលេខនេះមានអត្រាទាបជាងឆ្នាំមុនដែរ ។

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

ធនាគារជាតិ នៃ កម្ពុជា

NATIONAL BANK OF CAMBODIA

លេខ : ម.ហ.០៣៨

N° : M.F.038

# អាជ្ញាបណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

# MICROFINANCE INSTITUTION LICENSE

**ធនាគារជាតិ នៃ កម្ពុជា**

អនុញ្ញាតឱ្យ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ពីថល ភីអិលស៊ី** ធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានទីស្នាក់ការកណ្តាលតាំងនៅ ផ្ទះលេខ៥០២សេ & ៥០២ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ពីថល ភីអិលស៊ី** ត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងបទប្បញ្ញត្តិ សារាចរណែនាំ វិធាន ព្រមទាំងលក្ខខណ្ឌទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា។

**THE NATIONAL BANK OF CAMBODIA**

allows **MICROFINANCE AMATAK CAPITAL PLC** to carry out operations as microfinance institution with head office at N° 502C & 502D, Preah Monivong Blvd., Sangkat Tonle Basak, Khan Chamkar Mon, Phnom Penh.

MICROFINANCE AMATAK CAPITAL PLC shall abide by the Law on Banking and Financial Institutions and all regulations, circulars, rules, and conditions issued by the National Bank of Cambodia.

ថ្ងៃ ពុធ ៤កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០២៤

Phnom Penh, 24 July 2024

**ទេសាភិបាល**

Governor

ជា សិរី

- អាជ្ញាបណ្ណនេះ មានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ
- អាជ្ញាបណ្ណនេះ ត្រូវព្យួរបង្ហាញសាធារណជនគ្រប់ពេលវេលា

- This license is valid from the signing date.
- This license shall be displayed to the public at all times.

# Amatak Capital Organizational Chart



## ភាគទុនិកក្រុមហ៊ុន

អមតៈ ខាប់ភីថល ភីអិលស៊ី មានភាគទុនិកដ៏សំខាន់ពីរនាក់ដែលអ្នកទាំងពីរជាសហស្ថាបនិកក្រុមហ៊ុននេះ។

- **លោក តាន់ ថាបញ្ញា** គឺជាម្ចាស់ភាគហ៊ុនមួយ និងជាសហស្ថាបនិកផងដែរនៃក្រុមហ៊ុននេះ។ គាត់មានប្រវត្តិធ្វើជំនួញផ្សេងៗជាច្រើនទាំងនៅក្នុងទីផ្សារជាតិ និងអន្តរជាតិ។ យោងតាមជីវប្រវត្តិរបស់ក្រុមប្រឹក្សាភិបាល។
- **លោក តាន់ ថាភត្រា** គឺជាម្ចាស់ភាគហ៊ុនធំជាងគេ និងក៏ជាសហស្ថាបនិកផងដែរនៃក្រុមហ៊ុននេះ។ លោកមានប្រវត្តិសិក្សាដ៏ខ្ពស់លើផ្នែកហិរញ្ញវត្ថុ។ យោងតាមឯកសារជីវប្រវត្តិរបស់ក្រុមប្រឹក្សាភិបាល។

| ឈ្មោះ | ដើមទុនវិនិយោគ (USD) | ភាគរយនៃទុនវិនិយោគ |
|---|---|---|
| លោក តាន់ ថាបញ្ញា | ៧២០,០០០ | ៤៨% |
| លោក តាន់ ថាភត្រា | ៧៨០,០០០ | ៥២% |
| **សរុប** | **១,៥០០,០០០** | **១០០%** |



# ក្រុមប្រឹក្សាភិបាល

## លោក តាន់ ថាភត្រា ជាប្រធានក្រុមប្រឹក្សាភិបាល



លោក តាន់ ថាភត្រា គឺជាសហស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលផងដែរ។ លោកបានកើតនៅក្នុងប្រទេសកម្ពុជា និងបានទទួលការសិក្សានៅប្រទេសអូស្ត្រាលី លោក តាន់ ថាភត្រា បានបញ្ចប់បរិញ្ញាបត្រពាណិជ្ជកម្ម និងប្រព័ន្ធព័ត៌មានវិទ្យា។ ជាមួយនឹងចំណង់ចំណូលចិត្តផ្នែកហិរញ្ញវត្ថុ លោកក៏បានបន្តការសិក្សា និងបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុរបស់លោក (ដោយការស្រាវជ្រាវ) ។ នៅឆ្នាំ ២០០៨ លោកបានបញ្ចប់ការសិក្សាដោយទទួលបានថ្នាក់កិត្តិយសពីសាកលវិទ្យាល័យ Melbourne ។ បន្ទាប់ពីវិលត្រឡប់មកប្រទេសកម្ពុជាវិញ ដោយសារតែ លោក តាន់ ថាភត្រា ចង់មានចំណេះដឹងបន្ថែមក្នុងវិស័យហិរញ្ញវត្ថុ លោកបានចាប់យកបទពិសោធន៍ផ្ទាល់ខ្លួនបន្ថែមទៀតក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ នៅក្នុងពាក់កណ្ដាលឆ្នាំ ២០០៩ លោក តាន់ ថាភត្រា បានចូលកម្មសិក្សាការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុកមួយ។ បន្ទាប់មក លោកបានសម្រេចចិត្តយ៉ាងច្បាស់ក្នុងការបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយខ្លួនគាត់ផ្ទាល់ ដោយមានមូលហេតុពីរ។ ទីមួយ គឺដើម្បីសម្រេចចំណង់ចំណូលចិត្តរបស់លោកក្នុងវិស័យនេះ។ ទីពីរ គឺចង់ចូលរួមចំណែកលើការលើកស្ទួយជីវភាពប្រជាជនកម្ពុជាអោយកាន់តែប្រសើរឡើង។ ដោយមានការគាំទ្រពីក្រុមគ្រួសាររបស់លោកជាពិសេសបងប្រុសរបស់លោក (លោក តាន់ ថាបញ្ញា) អមតៈ ខាប់ភីថល ភីអិលស៊ី បានកើតឡើង ។

## លោក តាន់ ថាបញ្ញា

## នាយកគ្រប់គ្រងទូទៅ



លោក តាន់ ថាបញ្ញា គឺជាសហស្ថាបនិកម្នាក់ផ្សេងទៀត និងជានាយកគ្រប់គ្រង នៅអមតៈ។ លោក តាន់ ថាបញ្ញា បានកើតនៅក្នុងប្រទេសកម្ពុជាផងដែរ ប៉ុន្តែលោកបានទទួលការសិក្សាអប់រំនៅក្នុងប្រទេសអូស្ត្រាលី។ លោកបានបញ្ចប់សញ្ញាបត្របរិញ្ញាបត្រផ្នែកវិស្វកម្ម និងពាណិជ្ជកម្ម (ជំនាញសេដ្ឋកិច្ច)។ ខណៈពេលដែលកំពុងសិក្សាថ្នាក់អនុបណ្ឌិតផ្នែកពាណិជ្ជកម្មអន្តរជាតិនៅសាកលវិទ្យាល័យ Monash លោក តាន់ ថាបញ្ញា បានចូលរួមនៅក្នុងការបង្កើតអាជីវកម្មជាច្រើន ដែលរួមមានប្រតិបត្តិការហាងកាហ្វេ និងភេសជ្ជៈដែលទទួលបានជោគជ័យ នៅសាកលវិទ្យាល័យ RMIT។ លោកមានបទពិសោធន៍ជាច្រើនក្នុងការទំនាក់ទំនងជាមួយនិងគណៈកម្មាធិកាសាកលវិទ្យាល័យ បទពិសោធន៍នេះរួមជាមួយនឹងការចង់បានសេវាកម្មដ៏ល្អ បានជំរុញឱ្យសេវាកម្មបម្រើអតិថិជនរបស់អមតៈកាន់តែប្រសើរឡើង។ ក្រោយពីបញ្ចប់សញ្ញាបត្រអនុបណ្ឌិតរបស់លោក

នៅឆ្នាំ ២០០៩ លោក តាន់ ថាបញ្ញា បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ។ បើទោះបីជាលោក មិនទាន់ប្រាកដប្រជាពីអាជីពនេះក៏ដោយ ក៏លោកបានចូលបម្រើការងារនៅធនាគារ មេយប៊ែង ដែលអាចឱ្យគាត់ទទួលបានបណ្តាញទាក់ទងដ៏មានតម្លៃមួយនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ បន្ទាប់ពីបានចាកចេញពីធនាគារមេយប៊ែង លោក តាន់ ថាបញ្ញា បានចូលបម្រើការងារនៅស្ថានទូតអូស្ត្រាលី មានតួនាទីជាមន្ត្រីសវនកម្មទិដ្ឋាការ រយៈពេល៣ឆ្នាំ។ បទពិសោធន៍របស់លោកដែលទទួលបានពីបរិយាកាសការងារនេះ បានពង្រឹងតម្លៃស្នូលនៃភក្តីភាពរបស់លោកកាន់តែខ្លាំង សេចក្តីថ្លៃថ្នូរ និងក្រមសីលធម៌អាជីវកម្ម។ នៅអមតៈ លោក តាន់ ថាបញ្ញា មិនត្រឹមតែជាអ្នកដឹកនាំទេ តែលោកក៏ជាអ្នកផ្តល់នូវការគាំទ្រ និងការណែនាំក្នុងការលើកទឹកចិត្តបុគ្គលិក ឱ្យអនុវត្តការងារបានល្អប្រសើរផងដែរ។

## លោក សំណាង សីម៉ា
## ក្រុមប្រឹក្សាភិបាលឯករាជ្យ



លោក សំណាង សីម៉ា ជាក្រុមប្រឹក្សាភិបាលឯករាជ្យមួយរូបផ្សេងទៀត។ លោកមានដើមកំណើតនៅរាជធានីភ្នំពេញ តែបានចំណាយពេលជាច្រើនឆ្នាំដើម្បីទទួលការសិក្សានៅឯបរទេស។ គាត់ធ្លាប់រស់នៅប្រទេសសិង្ហបុរី ហើយបានទទួលការសិក្សារហូតដល់បញ្ចប់ថ្នាក់វិទ្យាល័យ។ លោក សីម៉ា ក៏បានបន្ត និងបញ្ចប់បរិញ្ញាបត្ររបស់គាត់ក្នុងជំនាញរដ្ឋបាលអាជីវកម្ម (Business Administration) នៅសាកលវិទ្យាល័យ Portsmouth ប្រទេសអង់គ្លេស។ បន្ទាប់ពីបានវិលត្រឡប់មកដល់ប្រទេសកម្ពុជាវិញ គាត់បានចូលប្រឡូកធ្វើអាជីវកម្មជាច្រើន ហើយធ្លាប់ទទួលជោគជ័យជាបន្តបន្ទាប់។ គាត់ក៏ធ្លាប់កាន់តំណែងជាច្រើននៅក្នុងជួរក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននានា។ លោក សីម៉ា មានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងវិស័យកសិកម្ម ជាពិសេសធ្លាប់មានក្រុមហ៊ុនវិនិយោគលើ កសិកម្មកប្បាស ឈ្មោះ Seladamex Co. , Ltd។ បច្ចុប្បន្ន លោក សីម៉ា បានបន្តមានវត្តមាននៅក្នុងឆាកអាជីវកម្ម គាត់បានវិនិយោគនៅក្នុងវិស័យជាច្រើនដូចជា៖ វិស័យទេសចរណ៍ អចលនទ្រព្យ កសិកម្ម និងវិស័យព័ត៌មានវិទ្យា។ បទពិសោធន៍ និងបណ្តាញលើវិស័យពាណិជ្ជកម្មដ៏ច្រើន នឹងផ្តល់អត្ថប្រយោជន៍ដល់ស្ថាប័នអមតៈ ខាប់ភីថល នាថ្ងៃអនាគត។

## លោកស្រី តាន់ សុគន្ធា
## សមាជិកក្រុមប្រឹក្សាភិបាល



លោកស្រី តាន់ សុគន្ធា គឺជាសមាជិកក្រុមប្រឹក្សាភិបាលនៅអមតៈ ។ លោកស្រី តាន់ សុគន្ធា បានធំធាត់ឡើង និងបានទទួលការសិក្សាអប់រំនៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី។ លោកស្រីទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យ Monash ។ ខណៈពេលដែលរស់នៅក្នុងប្រទេសអូស្ត្រាលីលោកស្រី តាន់ សុគន្ធា គឺបានធ្វើការនៅធនាគារក្នុងស្រុកមួយឈ្មោះធនាគារឃ្វីនឡែន។ លោកស្រីបានវិលត្រឡប់មកប្រទេសកម្ពុជា នៅឆ្នាំ ២០១១ លោកស្រីបានចូលបម្រើការងារក្នុងក្រុមការងារដែលទើបបង្កើតថ្មីនៅធនាគារ អេអិនហ្សិតរ៉ូយ៉ាល់ រហូតដល់បច្ចុប្បន្ន លោកស្រីកាន់តួនាទីជាអ្នកគ្រប់គ្រងការលក់សាជីវកម្ម និងពាណិជ្ជកម្ម។

## លោក តាន់ ថាភក្តី
## សមាជិកក្រុមប្រឹក្សាភិបាល



លោក តាន់ ថាភក្តី ជាសមាជិកក្រុមប្រឹក្សាភិបាលនៅ អមតៈ ខាប់ភីថល។ មុនពេលចូលជាសមាជិករបស់ អមតៈ នៅឆ្នាំ ២០១៦ លោកបានធ្វើជាអ្នកប្រឹក្សាយោបល់សម្រាប់ក្រុមហ៊ុន គាត់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការណែនាំអោយអ្នកវិនិយោគក្រៅប្រទេសមួយចំនួនបានស្គាល់ និងជួបប្រជុំជាមួយនឹងតំណាងស្ថាប័នអមតៈ។ លោកមានដើមកំណើតនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែបានទៅទទួលការសិក្សានៅឯប្រទេសអូស្ត្រាលី ហើយជាកន្លែងដែលគាត់បានទទួលសញ្ញាបត្របណ្ឌិត ផ្នែកគ្រប់គ្រង ពីសាកលវិទ្យាល័យដែលមានកិត្យានុភាពខ្ពស់ គឺសាកលវិទ្យាល័យ Melbourne នៃ ប្រទេសអូស្ត្រាលី។ បច្ចុប្បន្ន លោក ភក្តី កំពុងអនុវត្តគម្រោងមួយចំនួនដូចជារៀបចំផ្សារភ្ជាប់ និងផ្តល់ព័ត៌មានសំខាន់ៗ ជូនអ្នកវិនិយោគអន្តរជាតិដែលកំពុងស្វែងរកឱកាសបង្កើតពាណិជ្ជកម្ម ឬស្វែងរកដៃគូក្នុងប្រទេសកម្ពុជា។ ប្រវត្តិនៃការសិក្សាដ៏លេចធ្លោរបស់លោក ភក្តី ផ្គួបផ្សំជាមួយបណ្តាញអាជីវកម្មអន្តរជាតិ របស់គាត់នឹងផ្តល់ជាអត្ថប្រយោជន៍ជាច្រើនដល់ស្ថាប័ន អមតៈ នៅពេលអនាគត។

## លោក ហេង វុឌ្ឍី

## នាយកដ្ឋានប្រតិបត្តិការ



លោក ហេង វុឌ្ឍី បានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ នៅចុងឆ្នាំ ២០១៤ មានមុខតំណែងជាប្រធាននាយកដ្ឋានប្រតិបត្តិការ។ លោក វុឌ្ឍី មានបទពិសោធន៍ច្រើនក្នុងវិស័យមីក្រូហិរញ្ញវត្ថុ គាត់បានចាប់ផ្តើមអាជីពដំបូងជាមន្រ្តីឥណទានជាមួយធនាគារ Acleda អស់រយៈពេលជាង ៥ ឆ្នាំ។ បន្តមកទៀត គាត់បានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Green Central។ នៅក្នុងឆ្នាំ ២០០៨ ក៏បានទទួលមុខតំណែងជាប្រធានផ្នែកនាយកដ្ឋានឥណទាន។ ការខិតខំប្រឹងប្រែង និងភាពដឹកនាំដ៏ឆ្លាតវៃរបស់លោកវុឌ្ឍី បានជំរុញឱ្យគាត់ទទួលបានជោគជ័យ ហើយថ្នាក់ដឹកនាំបានបន្ថែមការងារ និងមុខតំណែងក្នុងនាយកដ្ឋានប្រតិបត្តិការ។ ដោយចង់បានការអភិវឌ្ឍន៍បន្តទៅមុខទៀត លោក ហេង វុឌ្ឍី បានផ្លាស់ប្តូរការងារមកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ គាត់បានចូលរួមអស់ពីកម្លាំងកាយចិត្តដើម្បីពង្រឹងវប្បធម៌ក្នុងនាយកដ្ឋានឥណទានរបស់ស្ថាប័នយើង។

## លោកស្រី អោ ទិត្យកក្កដា

## នាយកដ្ឋានហិរញ្ញវត្ថុ



លោកស្រី អោ ទិត្យកក្កដា បានកើត និងធំធាត់ឡើងនៅទីក្រុងភ្នំពេញប្រទេសកម្ពុជា។ លោកស្រីបានចូលប្រឡូកក្នុងវិស័យហិរញ្ញវត្ថុដោយឥតបានព្រាងទុកគោលដៅរបស់លោកស្រីពីមុន គឺចង់ធ្វើការក្នុងវិស័យទេសចរណ៍។ ផ្អែកលើភស្តុតាងលើការសិក្សារបស់លោកស្រី ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញទេសចរណ៍នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លោកស្រីបានចាប់ផ្តើមអាជីពជាបេឡាធិការ ធ្វើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ក្នុងឆ្នាំ២០០៧។ បទពិសោធន៍នេះ បានប្រែក្លាយលោកស្រីឱ្យមានចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅវិញ និងនៅក្នុងឆ្នាំ២០១១ លោកស្រីត្រូវបានជ្រើសរើសជាបុគ្គលិកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្រ្វីន បន្ទាប់មកទៀតបានក្លាយជាប្រធានគណនេយ្យករប្រចាំក្រុមហ៊ុន។ លោកស្រី អោ ទិត្យកក្កដា បានចូលបម្រើការងារនៅអមតៈ នៅដើមឆ្នាំ ២០១៣ ជាកន្លែងដែលលោកស្រីបានរួមចំណែកការងារយ៉ាងខ្លាំងក្នុងនាយកដ្ឋានទាំងពីររបស់យើង គឺនាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ ។

## លោក ថុល វុទ្ធា
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង



លោក ថុល វុទ្ធា មានដើមកំណើត និងបានទទួលការសិក្សានៅខេត្តកំពង់ចាម។ នៅឆ្នាំ ២០០៩ លោកបានទទួលសញ្ញាបត្រសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅសាលាជាតិអភិវឌ្ឍន៍ ខេត្តកំពង់ចាម។ លោក វុទ្ធា បានចាប់ផ្តើមអាជីពដំបូងរបស់លោកជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ ក្នុងឆ្នាំ ២០០៨ មានតួនាទីជាមន្ត្រីឥណទាន។ ដោយមានការចង់អភិវឌ្ឍន៍ចំណេះដឹង លោកបានសម្រេចចិត្តចូលមកបម្រើការងារនៅក្នុងនាយកដ្ឋានសវនកម្មផ្ទៃក្នុង អស់រយៈពេលពីរឆ្នាំ។ នៅឆ្នាំ ២០១៧ លោក វុទ្ធា បានបន្តពង្រឹងសមត្ថភាពខ្លួនដោយបានទទួលតំណែងជាប្រធានក្រុមសវនកម្មផ្ទៃក្នុងនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លីហួរ។ លោកបានថ្នាក់ដឹកនាំប្រគល់សិទ្ធិ ដើម្បីដឹកនាំសមាជិកសវនករដើម្បីចុះត្រួតពិនិត្យគ្រប់សាខា។ លោក ថុល វុទ្ធា បានចូលបម្រើការងារជាមួយ អមតៈ ខាប់ភីថល ភីអិលស៊ី នៅឆ្នាំ ២០១៨ ហើយត្រូវបានថ្នាក់ដឹកនាំប្រគល់តួនាទីសម្រាប់គ្រប់គ្រងនាយកដ្ឋានសវនកម្មទាំងមូល។

## លោក រួន ពុតសៅមី
## នាយកដ្ឋានព័ត៌មានវិទ្យា



លោក រួន ពុតសៅមី មានដើមកំណើតនៅខេត្តពោធិ៍សាត់ គាត់បានទទួលការអប់រំ និងចំណេះវិជ្ជាពីសាកលវិទ្យាល័យបៀលប្រាយ។ នៅក្នុងឆ្នាំ ២០២១ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ជំនាញផ្នែកសរសេរកម្មវិធី និង Database។ នៅពេលកំពុងសិក្សា លោក បានឆ្លៀតពេលចូលបម្រើការងារនៅក្រុមហ៊ុនឈ្មោះ TSD ដែលជាក្រុមហ៊ុនជំនាញផ្នែកសរសេរកម្មវិធី សម្រាប់គ្រប់គ្រងអាជីវកម្ម ខ្នាតតូច និងមធ្យម។ បទពិសោធន៍ដែលទទួលបានពីការងារនោះមានសារៈសំខាន់ សម្រាប់អនាគតរបស់គាត់។ លោកបានផ្លាស់អាជីពចូលមកវិស័យហិរញ្ញវត្ថុ នៅពាក់កណ្តាលឆ្នាំ ២០២១ តួនាទីជាមន្ត្រីព័ត៌មានវិទ្យា ដែលទទួលបន្ទុកលើការអភិវឌ្ឍន៍កម្មវិធី និងរបាយការណ៍ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី។ ដោយឃើញពីសមត្ថភាព និងការប្រឹងប្រែងរបស់គាត់ ថ្នាក់គ្រប់គ្រងដំឡើងតួនាទីជាប្រធានផ្នែកព័ត៌មានវិទ្យា និងផ្តល់សិទ្ធិអោយលោកទទួលខុសត្រូវលើនាយកដ្ឋានព័ត៌មានវិទ្យាទាំងមូល។ នៅពាក់កណ្តាលឆ្នាំ ២០២៣ ដោយលោកមើលឃើញពីសក្តានុពលលើវិស័យបច្ចេកវិទ្យា លោកបានបន្តការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រកុំព្យូទ័របន្ថែមទៀត។

## លោកស្រី សុរិន្ទ សុជាតិ

## នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល



លោកស្រី សុរិន្ទ សុជាតិ មានស្រុកកំណើតនៅខេត្តព្រៃវែង។ លោកស្រី ទទួលបានសញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ ពីស៊ីអាយឌីអេច (វិទ្យាស្ថានអភិវឌ្ឍសិទ្ធិមនុស្សនៅកម្ពុជា) និងទទួលបានបរិញ្ញាបត្រពីសាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជា ជំនាញផ្នែកហិរញ្ញវត្ថុ និងធនាគារ។ លោកស្រី មានបទពិសោធន៍យ៉ាងច្រើនក្នុងវិស័យហិរញ្ញវត្ថុ ធនធានមនុស្ស និងរដ្ឋបាលជាមួយអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នឯកជន និងក្នុងវិស័យផ្សេងៗទៀត។ លោកស្រី បានចូលរួមជាមួយអង្គការចំនួនពីរ គឺអង្គការកាត់បន្ថយអាវុធ និងអង្គការមូលនិធិសិទ្ធិកុមារ អស់រយៈពេលប្រហែលជាង ១៣ ឆ្នាំ ដែលមុខតំណែងចុងក្រោយរបស់លោកស្រី គឺជាប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល។ ក្រោយមក លោកស្រី ទទួលបានការងារនៅក្រុមហ៊ុនវេសឡាញអេឌ្យូខេសិនគ្រុប ជាអ្នកសម្របសម្រួលផ្នែកធនធានមនុស្ស និងប្រតិបត្តិការ អស់រយៈពេលជាងមួយឆ្នាំ។ បន្ទាប់មកទៀត លោកស្រី បានផ្លាស់ប្តូរការងារទៅក្រុមហ៊ុនក្រម៉ា (Krawma & Associates Co., Ltd) ដែលជាក្រុមហ៊ុន ផ្តល់សេវាកម្មគេហទំព័រឈានមុខគេនៅកម្ពុជាហៅថា "បងធំ" អស់រយៈពេលជិត ២ឆ្នាំ។ លោកស្រី សុរិន្ទ សុជាតិ បានចូលរួមជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី នៅចុងឆ្នាំ ២០១៩ ទទួលមុខតំណែងជាប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល ដែលនៅទីនេះលោកស្រីមានបំណងសំខាន់នោះ គឺការលើកកម្ពស់បរិយាកាសការងារ និងសុខមាលភាពល្អនៅកន្លែងធ្វើការ។ លោកស្រី ជឿជាក់ថាការផ្តល់នូវកន្លែងធ្វើការមួយដែលល្អ និងមានជាសុខភាព គឺជាយុទ្ធសាស្ត្រដ៏ល្អមួយក្នុងការទាក់ទាញ និងរក្សាបុគ្គលិក ព្រមទាំងលើកទឹកចិត្តពួកគេឱ្យខិតខំបំពេញការងារជាមួយនឹងការប្តេជ្ញាចិត្តយ៉ាងម៉ឺតមាំ ដើម្បីទទួលបានលទ្ធផលល្អបំផុតសម្រាប់ក្រុមហ៊ុន និងលើកកម្ពស់កេរ្តិ៍ឈ្មោះក្រុមហ៊ុនផងដែរ។

## ផលិតផល និងអតិថិជន




### ផលិតផល និងសេវាកម្ម

នៅក្នុងឆ្នាំ ២០១៣ អមតៈបានសាកល្បងផលិតផលប្រាក់កម្ចី ៤ ប្រភេទ ប៉ុន្តែមកដល់ឆ្នាំ ២០១៦ ស្ថាប័នបានបង្កើតឱ្យមានផលិតផលថ្មីពីរទៀត។ ដូចគ្នានេះដែរ នៅក្នុងឆ្នាំ ២០១៧ ស្ថាប័នបានបន្ថែមអោយមានផលិតផលមួយទៀតដែលមានឈ្មោះថា ឥណទានកាតគ្រី (VRC)។ ផលិតផលទាំងនេះរួមមាន ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន ឥណទានសម្រាប់ទិញម៉ូតូ ឥណទាន Tuk Tuk ឥណទានVRC ឥណទានអាជីវកម្មខ្នាតតូចបំផុត ឥណទានជំនួញខ្នាតតូច និងឥណទានអាជីវកម្មខ្នាតមធ្យម។ ដោយផ្អែកលើការឆ្លើយតបជាវិជ្ជមាន អមតៈ ខាប់ភីថល បានផ្តល់ផលិតផលទាំងនោះដល់អតិថិជនរបស់ខ្លួនជាផ្លូវការ។

## ប្រភេទនៃប្រាក់កម្ចី

### ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន

នាពេលបច្ចុប្បន្ននេះ ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួនត្រូវបានផ្តល់ដល់អតិថិជនដែលកំពុងរស់នៅក្នុងរាជធានីភ្នំពេញ និងធ្វើការងារនៅក្នុងវិស័យឯកជន។ យើងបានឱ្យនិយមន័យបុគ្គលទាំងនេះ ថាជាបុគ្គលិករបស់ក្រុមហ៊ុនឯកជន។ គោលបំណងនៃប្រាក់កម្ចីនេះ គឺដើម្បីផ្តល់នូវជម្រើសប្រភពនៃការផ្តល់ហិរញ្ញវត្ថុបន្ថែមដើម្បីទិញទំនិញប្រើប្រាស់ក្នុងគ្រួសារ (ឧ. ទូទឹកកក ម៉ាស៊ីនបោកគក់) ដែលចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ។ សម្រាប់ឥណទានប្រើប្រាស់ផ្ទាល់ខ្លួននេះ អមតៈមិនតម្រូវឱ្យមានទ្រព្យបញ្ចាំឡើយ ការរៀបចំផ្តល់ឥណទាននេះបាន គឺផ្អែកលើកម្រិតនៃប្រាក់ចំណូលរបស់អតិថិជនដែលមានស្ថិរភាព។ តារាងទី១ គឺបង្ហាញពីឧទាហរណ៍ នៃលក្ខខណ្ឌសម្រាប់ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន និងអត្រាការប្រាក់។

### ឥណទានសម្រាប់ទិញម៉ូតូ

ឥណទានសម្រាប់ទិញម៉ូតូ មានភាពស្រដៀងនិងឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនដែរ។ ឥណទានសម្រាប់ទិញម៉ូតូ ត្រូវបានផ្តល់ដល់អតិថិជនដែលកំពុងរស់នៅក្នុងរាជធានីភ្នំពេញ និងធ្វើការងារនៅក្នុងវិស័យ ឯកជន។ គោលបំណងនៃប្រាក់កម្ចីនេះ គឺដើម្បីផ្តល់នូវជម្រើសប្រភពនៃការផ្តល់ហិរញ្ញវត្ថុបន្ថែម ដើម្បីទិញ ម៉ូតូម្រាប់អតិថិជនដែលពុំមានប្រាក់សន្សំគ្រប់គ្រាន់។ សម្រាប់ឥណទានទិញម៉ូតូនេះ អមតៈ មិនតម្រូវឱ្យមានទ្រព្យដាក់បញ្ចាំឡើយ រីឯរយៈពេលកម្ចី គឺអាចផ្តល់បានទៅដល់ ៤៨ ខែ។ តារាងទី១ គឺបង្ហាញនូវឧទាហរណ៍នៃលក្ខខណ្ឌសម្រាប់ប្រាក់កម្ចីទិញម៉ូតូ និងអត្រាការប្រាក់។

### ឥណទាន Tuk Tuk

ឥណទាន Tuk Tuk ត្រូវបានបង្កើតឡើងសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមួយចំនួនរួចទៅហើយ ប៉ុន្តែគាត់មានគោលបំណងចង់ក្លាយជាម្ចាស់រ៉ឺម៉កកង់បីដើម្បីបង្កើតប្រាក់ចំណូលបន្ថែមទៀត។ ផលិតផលនេះមិនតម្រូវឱ្យអតិថិជនដាក់ទ្រព្យបញ្ចាំដើម្បីការពារហានិភ័យនោះទេ។ ប្រភេទប្រាក់កម្ចីនេះ ត្រូវបានកំណត់រយៈពេលអតិបរមាបានត្រឹម ៤៨ ខែ។ តារាងទី ១ សង្ខេបលម្អិតនៃលក្ខខណ្ឌសម្រាប់ប្រាក់កម្ចី រ៉ឺម៉កកង់បី។

### ឥណទាន កាតគ្រី

ឥណទាន VRC ត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលមានយានយន្តផ្ទាល់ខ្លួន ហើយប្រើប្រាស់កាតគ្រីវថយន្តជាទ្រព្យធានាដើម្បីទទួលបានកម្ចីពីស្ថាប័ន។ ប្រភេទកម្ចីនេះ អនុញ្ញាតឱ្យអតិថិជនទទួលបានកម្ចីរយៈខ្លីសម្រាប់ដោះស្រាយបញ្ហាលំហូរសាច់ប្រាក់។ ចំនួនសាច់ប្រាក់កម្ចីមានភាពខ្ពស់ជាងកម្ចីប្រភេទឥណទានផ្ទាល់ខ្លួន អតិថិជនអាចទទួលបានកម្ចីរហូតដល់ ៥,០០០ ដុល្លារ។

## ឥណទាន ទិញឡាន

នៅពេលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាកំពុងបន្តអភិវឌ្ឍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពប្រសើរឡើងនោះ មានអតិថិជនកាន់តែច្រើនដែលកំពុងជ្រើសរើសទិញរថយន្តជាលើកដំបូង។ គ្រឹះស្ថានអមតៈ មានបំណងចង់ផ្តល់ជម្រើសហិរញ្ញវត្ថុមួយដ៏សាមញ្ញបំផុតសម្រាប់អតិថិជនទាំងនោះ ដែលអាចមានលទ្ធភាពទិញ រថយន្តតាមផលិតផលប្រាក់កម្ចីទិញឡានរបស់យើង។ ប្រាក់កម្ចីប្រភេទនេះ មានកំណត់ចំនួនអតិបរមាគឺ២ម៉ឺនដុល្លារ និងរយៈពេលខ្ចី ៦០ ខែ។

## ឥណទានអាជីវកម្មខ្នាតតូចបំផុត

ឥណទានអាជីវកម្មខ្នាតតូចបំផុត ត្រូវបានផ្តល់ជាពិសេសដល់អតិថិជនដែលស្ថិតនៅជីវភាពកម្រិតទី៣ ដែលមានប្រមាណជា៨០% នៃចំនួនប្រជាជនសរុប។ ស្ថិតនៅជីវភាពកម្រិតបន្ទាត់នេះ ប្រជាជនភាគច្រើននៅក្នុងក្រុមនេះធ្វើការងារដោយប្រើកម្លាំងពលកម្មច្រើនដូចជា វិស័យកសិកម្ម និងការធ្វើកសិកម្ម។ ដើម្បីទទួលបានឥណទានអាជីវកម្មខ្នាតតូចបំផុតនេះបាន អតិថិជនត្រូវមានវត្ថុបញ្ចាំ (អាចជាកម្មសិទ្ធិប្លង់ទន់ ឬប្លង់រឹង) និងអតិថិជនត្រូវតែមានអាយុយ៉ាងហោចណាស់ ១៨ ឆ្នាំឡើងទៅ។ ឥណទានប្រភេទនេះ អត្រាការប្រាក់ត្រូវបានកំណត់មិនអោយលើសពី ១៨% ក្នុងមួយឆ្នាំទេ។ តារាងទី១ បង្ហាញសេចក្តីសង្ខេបលក្ខខណ្ឌនៃឥណទានអាជីវកម្មខ្នាតតូចបំផុតនេះ ។

## ឥណទានអាជីវកម្មខ្នាតតូច

ឥណទានអាជីវកម្មខ្នាតតូចបាញ់ឆ្ពោះទៅរកអាជីវកម្មខ្នាតតូច និងបុគ្គលដែលធ្វើកាងារខ្លួនឯង ឬការងារលក្ខណៈគ្រួសារ។ ប្រភេទនៃអាជីវកម្មនេះ អាចរួមបញ្ចូលទាំងអ្នកលក់តាមផ្លូវ អ្នកលក់បន្លែ និងអ្នកលក់សាច់ ម្ចាស់ហាងទំនិញលក់រាយ និងអ្នកចែកចាយគ្រឿងទេស។ ឥណទានជំនួញខ្នាតតូច គឺមានទំហំត្រឹម ១០,០០០ ដុល្លារ និងត្រូវមានវត្ថុបញ្ចាំធានាប្រាក់កម្ចី។ ជាថ្មីម្តងទៀតអតិថិជនត្រូវតែមានអាយុចាប់ពី១៨ឆ្នាំ ឬលើស និងមានភស្តុតាងបញ្ជាក់ពីប្រភពចំណូលដែលបង្ហាញថាមានលទ្ធភាពសងបំណុលត្រឡប់វិញ។

## ឥណទានអាជីវកម្មខ្នាតមធ្យម

ដូចគ្នានេះដែរ ឥណទានដែលត្រូវបានចាត់ថ្នាក់ថាជាឥណទានទំហំមធ្យម ត្រូវបានផ្តល់ដល់អតិថិជនសម្រាប់ធ្វើអាជីវកម្ម ឬប្រើប្រាស់ផ្ទាល់ខ្លួនតាមតម្រូវការ។ ឥណទានអាជីវកម្មខ្នាតមធ្យមនោះ ផ្តោតសំខាន់លើប្រតិបត្តិការអាជីវកម្មដែលត្រូវការដើមទុនបង្វិល ឬប្រើប្រាស់សម្រាប់ពង្រីកមុខរបរ។ អតិថិជនក៏អាចយកកម្ចីនេះ ដើម្បីប្រើប្រាស់សម្រាប់កែលម្អផ្ទះរបស់គាត់ផងដែរ។ ការគាំទ្រក្នុងការផ្តល់ឥណទានសម្រាប់ពាណិជ្ជកម្ម និងបុគ្គល គឺជាមធ្យោបាយដ៏សំខាន់មួយដើម្បីជួយឱ្យអមតៈបង្កើតបានជាបណ្តាញដ៏ល្អក្នុងសង្គម និងបង្កើតបានជានិមិត្តរូបរបស់ខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុល្បីឈ្មោះមួយ។ ប្រាក់កម្ចីអាជីវកម្មខ្នាតមធ្យម ត្រូវមានទ្រព្យបញ្ចាំដូចជាប្លង់រឹង ឬយ៉ាងហោចណាស់ក៏មានប្លង់ទន់ដែលត្រូវបានទទួលស្គាល់នៅថ្នាក់ស្រុក។

### តារាងទី១ – លក្ខណៈពិសេសនៃផលិតផលឥណទានរបស់អមតៈ ខាប់ភីថល

| ប្រភេទនៃឥណទាន | រយៈពេលខ្ចី (គិតជាខែ) | អត្រាការប្រាក់ក្នុងមួយខែ | ទំហំឥណទាន ដុល្លារ (ស្មើជារៀល) | ទ្រព្យដាក់ធានា |
|---|---|---|---|---|
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | រហូតដល់២៤ | ១.៥% | ១00-១,000 | មិនមាន |
| ឥណទានសម្រាប់ទិញម៉ូតូ | រហូតដល់៤៨ខែ | ១.២៥% | ១00-៥,000 | មិនមាន |
| ឥណទានសម្រាប់ Tuk Tuk | រហូតដល់៤៨ខែ | ១.៥% | ១00-៣,000 | មិនមាន |
| ឥណទានកាតគ្រី | រហូតដល់៤៨ខែ | ១.៥% | ១,00១-៥,000 | មិនមាន |
| ឥណទានឡាន | រហូតដល់៦០ខែ | ១.៣% - ១.៥% | ១,00១-២0,000 | មិនមាន |
| ឥណទានអាជីវកម្មខ្នាតតូច | រហូតដល់៤៨ខែ | ១.៥% | ១00-៣,000 | មាន |
| ឥណទានអាជីវកម្មខ្នាតតូច | រហូតដល់៧២ | ១.៤% | ៣,00១-១0,000 | មាន |
| ឥណទានអាជីវកម្មខ្នាតមធ្យម | រហូតដល់៩៦ខែ | ១.២% | ១0,00១-៧0,000 | មាន |




សម្រាប់ឆ្នាំ ២០២៤ នេះ ការផ្តល់ប្រាក់កម្ចីសម្រាប់វិស័យសេវាកម្មមានទំហំធំជាងគេនៃចំនួនសមតុល្យឥណទានសរុប គឺមានចំនួនប្រហែល ៦,៤៦០ លានរៀល។ គណនីសម្រាប់កម្ចីប្រភេទនេះមានចំនួនសរុបជាង ៨១៥ គណនី ហើយជាមធ្យមភាគគណនីនេះមានទឹកប្រាក់កម្ចីចំនួន ៧,៩៣ លានរៀល ។ ផ្ទុយទៅវិញមធ្យមភាគនៃគណនីកម្ចីសម្រាប់អ្នកដែលធ្វើអាជីវកម្ម គឺមានទំហំធំជាងគេដល់ ១០,៣ លានរៀល។

សមតុល្យឥណទានមានចំនួន ១,៩១៩ លានរៀល ដែលផ្តល់ជូនអាជីវករសរុបជាង ១៨៦ គណនី នេះបង្ហាញឱ្យឃើញថាអតិថិជនដែលប្រកបជំនួញ និងពាណិជ្ជកម្មជាធម្មតាតែងតែមានតម្រូវការទៅលើឥណទានខ្នាតមធ្យម។ ឥណទានសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ មានសមតុល្យឥណទានសរុបជាង ៥,៨៤៨ លានរៀល និងមានគណនីសរុបចំនួន៦៨០។ ប្រាក់កម្ចីសម្រាប់វិស័យកសិកម្ម និងសំណង់នៅសល់បន្ទាប់ពីឥណទានសរុបដកជាមួយ ឥណទានសម្រាប់វិស័យផ្សេងៗខាងលើរួចមក។ អមតៈ មានការិយាល័យតែ ៣ ប៉ុណ្ណោះ ហើយមានទីតាំងស្ថិតនៅរាជធានីភ្នំពេញទាំងអស់។ នាពេលអនាគត ស្ថាប័នចង់ពង្រីកប្រតិបត្តិការរបស់ខ្លួនបន្ថែមទៀត តាមរយៈការបើកសាខាបន្ថែមទៀត យើងសង្ឃឹមថានឹងបន្តពង្រីងការបង់រំលស់សម្ភារៈឱ្យកាន់តែមានភាពទូលំទូលាយជាងមុន ជាពិសេសគឺឥណទានម៉ូតូ។



## សង្ខេបផ្នែកប្រតិបត្តិការ

| | ២០២២ (IFRS SME) | ២០២៣ (IFRS SME) | ២០២៤ (IFRS SME) | % |
|---|---|---|---|---|
| **តំបន់ប្រតិបត្តិការ** | | | | |
| ចំនួនភូមិ | ៤០៥.00 | ៤០៥.00 | ៤០៥.00 | 0.00% |
| ចំនួនឃុំ/សង្កាត់ | ១៤៨.00 | ១៤៨.00 | ១៤៨.00 | 0.00% |
| ចំនួនខណ្ឌ/ស្រុក | ៣.00 | ៣.00 | ៣.00 | 0.00% |
| ចំនួនសាខា | ៣.00 | ៣.00 | ៣.00 | 0.00% |
| **សមតុល្យឥណទាន** | | | | |
| សមតុល្យឥណទានសរុប | ៤,៥២០,៩៩៥ | ៤,៤៩៩,៨៦០ | ៤,៣១៩,០៥៥ | -៤.០២% |
| ចំនួនអតិថិជន | ១,៩៨២.00 | ២,១១៣.00 | ២,០៧៦.00 | -១.៧៥% |
| សមតុល្យឥណទានជាមធ្យម | ២,២៨១.០៣ | ២,១២៩.៦១ | ២,០៨០.៤៧ | -២.៣១% |
| អ្នកខ្ចីជាស្ត្រី | ៨៩៨.00 | ៩១៦.00 | ៨៧៩.00 | -៤.០៤% |
| សមតុល្យឥណទានសម្រាប់ភ្នាក់ងារឥណទានម្នាក់ | ១៩៦,៥៦៥.០ | ២១៤,២៧៩.០ | ១៩៦,៣២០.០ | -៨.៣៨% |
| ចំនួនអតិថិជនសម្រាប់ភ្នាក់ងារឥណទានម្នាក់ | ៨៦.១៧ | ១០០.៦២ | ៩៤.៣៦ | -៦.២២% |
| ចំនួនភ្នាក់ងារឥណទាន | ២៣.00 | ២១.00 | ២២.00 | -៤.៧៦% |
| **ការបញ្ចេញឥណទាន** | | | | |
| ចំនួនឥណទានដែលបានបញ្ចេញ | ៤,៦៩៨,៥០៥ | ៤,០៩២,៣០៩ | ៣,៥៦០,៨៧៨ | ១២.៩៩% |
| ចំនួនអតិថិជនដែលបានខ្ចី | ១,៩៦៥.00 | ២,០៥២.00 | ១,៩៤៧.00 | -៥.១២% |
| បញ្ចេញឥណទានជាមធ្យម | ២,៣៩១.១០ | ១,៩៩៤.៣០ | ១,៨២៨.៩១ | -៨.២៩% |
| **ឥណទានដែលមានហានិភ័យ** | | | | |
| ចំនួនឥណទានដែលមានហានិភ័យ>៣០ថ្ងៃ | ១៥១,៦៣៩ | ១៣៧,៥៣៨ | ២៤៨,០២៧ | ៨០.៣៣% |
| ភាគរយនៃឥណទានដែលមានហានិភ័យ>៣០ថ្ងៃ | ៣.៣៥% | ៣.០៦% | ៥.៧៤% | ៨៧.៨៤% |
| **ឥណទានដែលបានលុបចេញ** | | | | |
| ចំនួនឥណទានដែលបានលុបចេញ | ៨,២០៨.៦៣ | ២៧,២៨២.៣ | ៤៨,៣៥៥.២៩ | ៧៧.២៤% |
| សមាមាត្រឥណទានដែលបានលុបចេញ | 0.១៨% | 0.៦១% | ១.១២% | - |

### *ប្រតិបត្តិការ*

បច្ចុប្បន្ន គ្រឹះស្ថាន អមតៈ ខាប់ភីថល មានសាខាចំនួន៣ ដែលមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ។ តាមរយៈភ្នាក់ងារឥណទានរបស់យើងដែលបានបំពេញការងារដ៏សកម្ម យើងអាចផ្តល់សេវាហិរញ្ញវត្ថុដោយគ្របដណ្តប់ស្ទើរតែពេញរាជធានីទាំងមូល។ ជាក់ស្តែង តំបន់ប្រតិបត្តិការរបស់យើងមានសរុបជាង ៤០៥ ភូមិ

ក្នុងចំនួន ១៤៨ ឃុំ/សង្កាត់។ យើងបានផ្តល់ប្រាក់កម្ចីដល់អតិថិជនចំនួន ២,០៧៦ គ្រួសារ ដែលមានប្រាក់កម្ចីសរុបចំនួនជាង ៤,៣ លានដុល្លារ។ អមតៈ បានផ្តល់ប្រាក់កម្ចីជូនអតិថិជនដែលជាស្រ្តីចំនួន ៨៧៩ នាក់ តួលេខនេះ មានការធ្លាក់ចុះជាងឆ្នាំមុនប្រមាណ ៤%។ តួលេខនេះ គឺជាអត្រាមួយដែលថ្នាក់ថ្នាក់ដឹកនាំបានរំពឹងទុក ស្ថាប័នសង្ឃឹមថា អត្រាអតិថិជនដែលជាស្រ្តីអាចកើនដល់ ៥០% នៃអតិថិជនសរុប។ សមតុល្យឥណទានជាមធ្យម គឺស្ថិតនៅចន្លោះ ១,៩៤៧ ដុល្លារដែលស្របជាមួយនឹងគោលដៅផែនការរបស់អមតៈ។ ជាអកុសល លទ្ធផលបញ្ចេញឥណទានសម្រាប់ឆ្នាំ ២០២៤ ឃើញថាចំនួនអតិថិជនបានថយចុះជាង ៥% និងចំនួនសមតុល្យឥណទានសរុបបានធ្លាក់ចុះជាង ៤% គិតជាទឹកប្រាក់មានចំនួនជាង ៤,៣ លានដុល្លារប៉ុណ្ណោះ។ យើងសង្ឃឹមថាជាមួយនឹងទិសដៅយុទ្ធសាស្រ្តថ្មីដែលបានកំណត់សម្រាប់ឆ្នាំក្រោយ ស្ថាប័នអាចចាប់ផ្តើមកសាងឡើងវិញនូវចំនួនប្រាក់កម្ចីរបស់ខ្លួន ហើយត្រលប់ទៅរកប្រាក់ចំណេញវិញម្តងទៀត។

## ការបញ្ចេញឥណទាន




សមតុល្យឥណទានរបស់ស្ថាប័ននៅដើមឆ្នាំ ២០២៤ មានត្រឹមតែជាង ៤,៤៣ លានដុល្លារប៉ុណ្ណោះ ហើយតួលេខនេះឃើញមិនមានការរីកចម្រើនពេញមួយឆ្នាំ។ មានកត្តាសំខាន់ពីរដែលបណ្តាលឱ្យកំណើនប្រាក់កម្ចីនៅទ្រឹង។ ទី១ ដោយតម្រូវការឥណទានមានការធ្លាក់ចុះ បណ្តាលមកពីការងើបឡើងវិញយឺតនៃវិស័យមួយចំនួនដូចជា សំណង់ អចលនទ្រព្យ ទេសចរណ៍ និងការលក់ដុំ និងរាយ បាននាំឱ្យមានការកាត់បន្ថយតម្រូវការប្រាក់កម្ចី។ ទី២ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរួមទាំង អមតៈ ខាប់ភីថល កាន់តែមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការបញ្ចេញឥណទាន ចំពេលមានភាពមិនប្រាកដប្រជាខ្លាំងនៃសេដ្ឋកិច្ចពិភពលោក និងការធ្លាក់ចុះនូវគុណភាពឥណទាន។ ជាទូទៅថ្នាក់គ្រប់គ្រង និងក្រុមវាយតម្លៃប្រាក់កម្ចីបានចាប់ផ្តើតបន្ធូរបន្ថយការអនុម័តប្រាក់កម្ចីវិញនាត្រឹមចុងឆ្នាំប៉ុណ្ណោះ។ ជាក់ស្តែង បានសឱ្យឃើញក្នុងការកើនឡើងនៃអត្រាការផ្តល់កម្ចីនៅក្នុងខែវិច្ឆិកា។ ជារួមការធ្លាក់ចុះនៃតម្រូវការឥណទាន និងការរឹតបន្តឹងប្រាក់កម្ចីបានបន្តជិតពេញមួយឆ្នាំ

ហើយបានបណ្តាលឱ្យសមតុល្យឥណទាននៅសល់ត្រឹមតែ ៤,៣១ លានដុល្លារប៉ុណ្ណោះ។ យោងតាមការវិភាគក្រាហ្វខាងលើ យើងអាចសន្និដ្ឋានថា ការបញ្ចេញឥណទានរវាងឆ្នាំទាំងពីរ គឺមានភាពស្រដៀងគ្នាពីមួយខែទៅមួយខែ។ ប៉ុន្តែបរិមាណនៃការផ្តល់ប្រាក់កម្ចីនៅក្នុងឆ្នាំ ២០២៣ ភាគច្រើនគឺតែងតែមានសភាពខ្ពស់ជាងឆ្នាំ ២០២៤ លើកលែងតែខែវិច្ឆិកា។ ជាមធ្យមបរិមាណសម្រាប់ការបញ្ចេញឥណទាន គឺប្រហែល ៣៤១,000 ដុល្លារក្នុងមួយខែសម្រាប់ឆ្នាំ ២០២៣ និង ២៩៦,៧៤០ ដុល្លារ ក្នុងមួយខែសម្រាប់ឆ្នាំ ២០២៤។

## សមតុល្យឥណទានដែលមានហានិភ័យ




សមតុល្យឥណទានដែលមានហានិភ័យក្នុងឆ្នាំ ២០២៤ មានអត្រាជាង ៥,៧៤% តួលេខនេះមានអត្រាទាបជាងនឹងបទដ្ឋានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដែលជាមធ្យមអត្រានេះ គឺមានចំនួនលើស ៧,៤% ទៅទៀត។ ការកើនឡើងនៃឥណទានយឺតយ៉ាវឆ្លុះបញ្ចាំងពីបញ្ហាដែលកំពុងប្រឈមក្នុងស្ថាប័ន និងក្នុងវិស័យទាំងមូលផងដែរ។

ដោយយោងថាសេដ្ឋកិច្ចពិភពលោកនឹងបន្តជួបភាពរអាក់រអួល ជាពិសេសពីប្រទេសចិនដែលជាអ្នកវិនិយោគធំនៅជាងគេនៅកម្ពុជា ដូច្នេះថ្នាក់ដឹកនាំបានកំណត់គោលដៅអត្រាឥណទានមិនដំណើការសម្រាប់ឆ្នាំក្រោយមិនឱ្យលើស ៤,៥%។ គ្រប់នាយកដ្ឋានពាក់ព័ន្ធទាំងអស់ ត្រូវសហការគ្នាឱ្យបានជិតស្និទ្ធ ដើម្បីសម្រេចបានគោលដៅខាងលើនេះ។ នៅក្នុងឆ្នាំនេះ ឥណទានសំវិធានធនមានចំនួនជាង ២៤៨,000 ដុល្លារខ្ពស់ជាងឆ្នាំមុន ៨០,៣% ហើយស្ថាប័នបានលុបចោលឥណទាន ខាតបង់សរុបទឹកប្រាក់ ៤៨,000 ដុល្លារ បើធៀបនឹងឆ្នាំមុនដែលមានចំនួនដល់ជាង ២៧,000ដុល្លារ។

## សង្ខេបផែនការហិរញ្ញវត្ថុ

នាយកដ្ឋានហិរញ្ញវត្ថុ គឺទទួលបន្ទុករៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តតាមបទបញ្ញត្តិដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ច្បាប់ពន្ធ និងស្តង់ដារគណនេយ្យអន្តរជាតិ (IFRS for SME) ។

| | ២០២២ (IFRS SME) | ២០២៣ (IFRS SME) | ២០២៤ (IFRS SME) | ផ្លាស់ប្តូរ |
|---|---|---|---|---|
| សរុបទ្រព្យសកម្ម | ៤,៦៣៨,៧២៨.00 | ៤,៧០៣,៧៩២.00 | ៤,៣៩៦,៩៥៩.00 | -៦.៥២% |
| សមតុល្យឥណទានសរុប | ៤,៣៩០,២១៣.00 | ៤,៣៦៨,៩៤៤.00 | ៤,១១២,៩២១.00 | -៥.៨៦% |
| សរុបទ្រព្យអកម្ម | ២,៣៤៣,៩៤៩.00 | ២,៣៩៧,៩២៤.00 | ២,១៤៩,៤៧៦.00 | -៦.១៩% |
| សរុបមូលនិធិ | ២,២៩៤,៧៧៩.00 | ២,៣០៥,៨៦៨.00 | ២,១៤៧,៤៨៣.00 | -៦.៨៧% |
| សរុបចំណូល | ៨៧៣,៨១១.00 | ៩៨៨,២២៦.00 | ៩២១,៧៧០.00 | -៦.៧២% |
| ចំណាយថ្លៃប្រតិបត្តិការ | ៨៣៤,៦៦៨.00 | ៩៧៧,១៣៧.00 | ១,០៨០,៣២២.00 | ១០.៥៦% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | ៣៩,១៤៣.00 | ១១,០៨៩.00 | (១៥៨,៥៥២.00) | -១៥២៩% |
| ផលលើទ្រព្យសកម្មជាមធ្យម | 0.៨៤% | 0.២៤% | -៣.៦១% | -១៦២៩% |
| ផលលើមូលធនជាមធ្យម | ១.៧១% | 0.៤៨% | -៧.៣៨% | -១៦៣៥% |
| មូលធនធៀបនឹងទ្រព្យសកម្មសរុប | ៤៩.៤៧% | ៤៩.0២% | ៤៨.៨៤% | -0.៣៧% |
| បំណុលធៀបនឹងទ្រព្យសកម្មសរុប | ៥0.៥៣% | ៥0.៩៨% | ៥១.១៦% | 0.៣៦% |

### ប្រាក់ចំណេញ

ក្នុងឆ្នាំ ២០២៤ ប្រាក់ចំណេញសម្រាប់ស្ថាប័ន អមតៈ ខាប់ភីល បានធ្លាក់ចូលតំបន់អវិជ្ជមានជាលើកដំបូងដែលមិនធ្លាប់មានអស់រយៈពេលជាច្រើនឆ្នាំ ហើយចំនួននេះបានធ្លាក់ចុះដល់ -១៥៨,៥២២ ដុល្លារ។ តួលេខប្រាក់ចំណេញមានកម្រិតទាបជាងអ្វីដែលថ្នាក់គ្រប់គ្រងបានរំពឹងទុក។ កត្តាចម្បងដែលរួមចំណែកបង្កឱ្យប្រាក់ចំណេញមានចំនួនទាបគឺ៖ ទីមួយ ការបញ្ចេញកតណទានមិនបានកើនឡើងតាមផែនការរបស់ថ្នាក់គ្រប់គ្រង ដែលបណ្តាលឱ្យសមតុល្យឥណទានធ្លាក់ចុះខ្លាំងបើធៀបនឹងឆ្នាំមុន។ ទីពីរ ការចំណាយទូទៅរបស់ស្ថាប័នមានការកើនឡើងជាលំដាប់។ លើសពីនេះ គុណភាពឥណទានក៏កាន់តែមានភាពយ៉ាប់យ៉ឺនដែលតម្រូវឱ្យស្ថាប័នត្រូវលុបចោលនូវឥណទានមិនដំណើរការមួយចំនួនធំ។ ជាក់ស្តែង ការចំណាយលើប្រតិបត្តិការរបស់ស្ថាប័នបានកើនឡើងជាង ១០% ខណៈពេលដែលប្រាក់ចំណូលសរុបរបស់យើងបានធ្លាក់ចុះជាង៦,៧% ដែលបណ្តាលឱ្យចំនួនប្រាក់ចំណេញធ្លាក់ចុះយ៉ាងខ្លាំង។ ដូចគ្នានេះដែរ យើងទទួលបានលទ្ធផលមិនល្អសម្រាប់ផលលើទ្រព្យសកម្ម គឺអត្រា -៣,៦១% និងផលលើមូលធន ៧,៣៨% អត្រាទាំងពីរនេះ គឺធ្លាក់ចុះជាងឆ្នាំងមុន។ ទៅថ្ងៃអនាគត បុគ្គលិកគ្រប់ជាន់ថ្នាក់ត្រូវខិតខំពង្រឹងការងាររបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើនប្រាក់ចំណេញអោយដូចមុនវិញ។

## ទ្រព្យសកម្ម, ទ្រព្យអកម្ម និងមូលនិធិរបស់ភាគទុនិក

ក្នុងឆ្នាំ ២០២៤ ទ្រព្យសកម្មរបស់គ្រឹះស្ថានអមតៈ មានចំនួនជាង ៤,៤ លានដុល្លារ តួលេខនេះ គឺមានចំនួនទាបជាងឆ្នាំមុនបន្តិចបន្តួច។ ទ្រព្យអកម្មសម្រាប់ឆ្នាំនេះក៏បានធ្លាក់ចុះជាង ៦,២% ធៀបនឹងឆ្នាំមុន នេះក៏ដោយសារស្ថាប័នមិនបានស្នើកម្ចីបន្ថែមទៀតពីខាងក្រៅ ពីព្រោះតម្រូវការឥណទានពីសំណាក់អតិថិជនមានការថយចុះ។ រីឯមូលនិធិសរុបបានធ្លាក់ចុះជាង ៦,៩% ដែលមានចំនួនជាង ២,១៥ លានដុល្លារ ការថយចុះគឺបណ្តាលមកពីការប្រែប្រួលនៃលទ្ធផលបង្គរអវិជ្ជមានក្នុងឆ្នាំនេះ ហើយស្ថាប័នមិនបានចែកប្រាក់ចំណេញនោះទេ។ ប្រតិបត្តិការរបស់ អមតៈ ខាប់ភីថល ភីអិលស៊ី បានធ្វើហិរញ្ញប្បទានចម្បងដោយទុនវិនិយោគ និងកម្ចី ដូច្នេះហិរញ្ញវត្ថុបំណុលបានកើនឡើងត្រឹមតែ ចំនួន ១,០៥ ដងនៃកម្រិតមូលធនទាំងមូល។ មួយវិញទៀត កម្រិតនៃអនុបាតប្រសិទ្ធភាពប្រតិបត្តិការ គឺស្ថិតនៅអត្រាល្អប្រសើរ គឺ ៥០,២៧%។ តួលេខនេះបានបង្ហាញថាកម្រិតសោធនភាពនៅតែមានកម្រិតខ្ពស់នៅឡើយ ដូច្នេះអមតៈ នៅតែមានលទ្ធភាពទទួលប្រាក់កម្ចីបន្ថែមទៀតនាពេលអនាគត ។

## ប្រាក់កម្ចី

| ម្ចាស់បំណុល | ចំនួនដំបូង (ដុល្លារ) | សមតុល្យ (ដុល្លារ) | អត្រាការប្រាក់ |
|---|---|---|---|
| ធនាគារ (Phillip TL) $ | ៣៥0,000.00 | ១២៧,៧២៦.៩៩ | ៨.៧៥% ក្នុងមួយឆ្នាំ |
| ធនាគារ (Phillip OD) $ | ២00,000.00 | ១២៥,៣0៣.0៣ | ៩.0៥% ក្នុងមួយឆ្នាំ |
| ធនាគារ (Phillip OD) ៛ | ១00,000.00 | ៣៨,៦៨0.៤0 | ៩.0៥% ក្នុងមួយឆ្នាំ |
| ធនាគារ (Phillip TL) ៛ | ២00,000.00 | - | ៨.៧៥% ក្នុងមួយឆ្នាំ |
| ធនាគារ (RHB) $ | ៣00,000.00 | ៤១,៥៤៥.៥៨ | ៨% ក្នុងមួយឆ្នាំ |
| ធនាគារ (RHB OD) $ | ១00,000.00 | ៥៩,0២៣.៤៩ | ៨.២៥% ក្នុងមួយឆ្នាំ |
| ធនាគារ (Maybank OD) $ | ៧00,000.00 | ៤៩៣,២៤៨.៥១ | ៨% ក្នុងមួយឆ្នាំ |
| លោក តាន់ ថាភត្រា | ១៥0,000.00 | ១៥0,000.00 | ៨% ក្នុងមួយឆ្នាំ |
| លោក តាន់ ថាភត្រា | ១៥0,000.00 | ១៥0,000.00 | ៨% ក្នុងមួយឆ្នាំ |
| លោក តាន់ ថាភត្រា | ២០០,000.00 | ២00,000.00 | ៨% ក្នុងមួយឆ្នាំ |
| លោក តាន់ ថាភត្រា | ២០០,000.00 | ២00,000.00 | ៨% ក្នុងមួយឆ្នាំ |
| លោក តាន់ ថាភត្រា | ២០០,000.00 | ២00,000.00 | ៨% ក្នុងមួយឆ្នាំ |
| លោក តាន់ ថាភត្រា | ២០០,000.00 | ២00,000.00 | ៨% ក្នុងមួយឆ្នាំ |
| លោក តាន់ ថាភត្រា | ២00,000.00 | ២00,000.00 | ៨% ក្នុងមួយឆ្នាំ |
| សរុប | ៣,២៥០,០០០.០០ | ២,១៨៥,៥២៨.០០ | |

អមតៈ ខាប់ភីថល មានឱកាសសម្រាប់ប្រតិបត្តិការរបស់ខ្លួនដោយខ្ចីប្រាក់រយៈពេលវែងពីធនាគារពាណិជ្ជ និង ម្ចាស់ភាគហ៊ុនរបស់ខ្លួន។ អត្រាការប្រាក់ត្រូវបានចរចានៅត្រឹមចន្លោះ ៨% - ៩,០៥% ក្នុងមួយឆ្នាំដែលជាកម្រិតមួយប្រហែលនឹងទីផ្សារ។ នេះជាកត្តាដែលអាចឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រកួតប្រជែងកាន់តែខ្លាំងក្លាជាងមុនក្នុងការផ្តល់អត្រាការប្រាក់។ ធនាគារហ្វីលីព គឺជាធនាគារមួយក្នុងចំណោមអ្នកផ្គត់ផ្គង់ប្រាក់កម្ចីជូនដល់គ្រឹះស្ថានអមតៈ ឆ្នាំមុនស្ថាប័ននេះបានបង្កើនអត្រាការប្រាក់របស់ខ្លួន ០,២៥% ហើយរហូតមកដល់ឆ្នាំ ២០២៤ នេះ ធនាគារហ្វីលីព បានរក្សាអត្រានេះដដែល។

នៅឆ្នាំ ២០២៤ កម្ចីពីម្ចាស់ភាគហ៊ុនបានបង្គរដល់ចំនួន ១,៣ លានដុល្លារ ដែលមានអត្រាការប្រាក់ ៨% ក្នុងមួយឆ្នាំ។ ប្រាក់កម្ចីដែលបានពីម្ចាស់ភាគហ៊ុនត្រូវបានយកមកប្រើប្រាស់ដើម្បីគាំទ្រដល់កំណើននៃតម្រូវការរបស់អតិថិជន និងប្រតិបត្តិការទូទៅរបស់ស្ថាប័នផងដែរ។

## សមត្ថភាពរបស់បុគ្គលិក




នៅឆ្នាំ ២០២៤ អមតៈ ខាប់ភីថល មានបុគ្គលិក ៦៤ នាក់ បុគ្គលិកបុរសមាន ៤៤នាក់ និងស្ត្រីមាន ២០ នាក់។ ជារួម ៥៨% នៃបុគ្គលិករបស់យើង គឺជាបុគ្គលិកធ្វើការក្នុងការិយាល័យ និង៤២% គឺជាបុគ្គលិក ធ្វើការខាងក្រៅការិយាល័យ។ ទាក់ទងនឹងកម្រិតនៃការអប់រំ បុគ្គលិកមានបរិញ្ញាបត្រមានចំនួន ៨០% នៃចំនួនសរុបរបស់យើង ខណៈនេះមានបុគ្គលិកចំនួន ៦% ដែលទទួលបានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិត។ បុគ្គលិកដែលមានកម្រិតអប់រំទាបជាងគេនៅក្នុងស្ថាប័នរបស់យើង គឺសញ្ញាបត្រទុតិយភូមិ។




នៅឆ្នាំ ២០២៤ បុគ្គលិកលាឈប់ពីការងារមានចំនួនជាង ២០% ។ អត្រានៃការលាឈប់មានកម្រិតទាបជាងឆ្នាំបន្តិចបន្តួច ជាមួយគ្នានេះដែរចំនួននៃការជ្រើសរើសបុគ្គលិកថ្មីមានអត្រាស្មើ ២២% នៃបុគ្គលិកសរុបរបស់យើង។ ស្ថាប័នកំពុងធ្វើការផ្លាស់ប្តូរបន្តិចម្តងៗពីការពឹងផ្អែកលើមន្រ្តីឥណទានរបស់យើង ទៅកាន់វិធីសាស្រ្តដែលមានប្រសិទ្ធភាពជាងមុន ដោយប្រើជំនួយពីភ្នាក់ងារខាងក្រៅ និងហាងលក់ម៉ូតូវិញ។ វិធីសាស្រ្តនេះអាចជួយសម្រាលការចំណាយរបស់ស្ថាប័នទៅថ្ងៃអនាគត ជាពិសេសចំណាយទៅលើការជ្រើសរើសនិងថែរក្សាមន្រ្តីឥណទានល្អៗ។ ជាងនេះទៅទៀត ការធ្វើទីផ្សារតាមវិធីចាស់ប្រហែលជាហួសសម័យនៅក្នុងបរិយាកាសអាជីវកម្មបច្ចុប្បន្ន។ ផ្នែកទីផ្សាររបស់យើងត្រូវប្រើប្រាស់ប្រព័ន្ធអនឡាញដូចជា Facebook និង TikTok ដើម្បីផ្សព្វផ្សាយផលិតផល និងពង្រីកទីផ្សារ។



# របាយការណ៍សម្រង់
# សវនកម្មហិរញ្ញវត្ថុ
# ប្រចាំឆ្នាំ២០២៤

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០



**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

**សកម្មភាពចម្បង**

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺប្រតិបត្តិការសកម្មភាពមីក្រូហិរញ្ញវត្ថុ និងផ្តល់សេវាផ្សេងៗដែលទាក់ទងទៅនឹងសេវាកម្មហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

**លទ្ធផលនៃប្រតិបត្តិការ**

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ខាតសម្រាប់ការិយបរិច្ឆេទ | ១៥៨.៥៥២ | ៦៤៥.៤៦៥ |

**ភាគលាភ**

ក្រុមប្រឹក្សាភិបាលពុំបានណែនាំឱ្យមានការទូទាត់ភាគលាភសម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ននេះទេ។

**ទុនបម្រុង និងសំវិធានធន**

នៅក្នុងអំឡុងការិយបរិច្ឆេទ មានការផ្ទេរចំនួន ១០.៦២៣ដុល្លារអាមេរិក ពីទុនបម្រុងតាមច្បាប់ទៅចំណេញរក្សាទុក។

**បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ**

នៅមុនពេលដែលរបាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលបំណុលពិបាកទារ និងការធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថា បំណុលពិបាកទារទាំងអស់ត្រូវបានលុបចោល និងសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់បំណុលជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការលុបចោលបំណុលពិបាកទារ ឬចំនួនសំវិធានធនសម្រាប់បំណុលជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ជាសារវន្តឡើយ។

**ទ្រព្យសកម្មចរន្ត**

នៅមុនពេលរបាយការណ៍ចំណូលពេញលេញ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារ នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលរំពឹងទុកនឹងអាចលក់បានលើទីផ្សារ។

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០



**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)**

**ទ្រព្យសកម្មចរន្ត (ត)**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្ដាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

**វិធីសាស្ត្រកំណត់តម្លៃ**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង និងដែលអាចបណ្ដាលឱ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃ ដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម ឬបំណុលរបស់ក្រុមហ៊ុនឡើយ។

**បំណុលយថាហេតុ និងបំណុលផ្សេងៗ**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីការិយបរិច្ឆេទនេះ ឬ

(២) បំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីការិយបរិច្ឆេទនេះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីថ្ងៃការិយបរិច្ឆេទដែលនឹង ឬអាចមានការប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់សងនោះទេ។

**ការផ្លាស់ប្តូរនៃហេតុការណ៍**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនត្រូវបានរៃកញែកក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបណ្ដាលឱ្យមានចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានការភ័ន្តច្រឡំឡើយ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទនេះមិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរ ដែលកើតចេញពីកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះនៃចុងការិយបរិច្ឆេទ មកទល់នឹងថ្ងៃចេញរបាយការណ៍នេះ ពុំមានកត្តា ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត ឬមិនប្រក្រតីណាមួយបានកើតឡើង ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ ដែលរបាយការណ៍ត្រូវបានធ្វើឡើងឡើយ។

**ដើមទុន**

ក្រុមហ៊ុនពុំបានបោះផ្សាយភាគហ៊ុន នៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្ដល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្ដល់សិទ្ធជាភាគហ៊ុននៃក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ។

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០



**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)**

**សមាជិកក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការចាប់តាំងពីចេញរបាយការណ៍ចុងក្រោយរួមមាន៖

លោក តាន់ ថាភត្រា

លោក តាន់ ថាបញ្ញា

អ្នកនាង តាន់សុគន្ធា

លោក សំណាង ស៊ីម៉ា

លោក តាន់ ថាភក្តី

**អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល**

ក្នុងអំឡុង និងចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាភាគីមួយ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬលិខិត បំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដ៏ទៃមួយទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួលឬមានសិទ្ធិទទួលនូវ អត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬ ដោយក្រុមហ៊ុនពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងតែអត្ថប្រយោជន៍ដ៏ទៃទៀត ដែលអាចកើតឡើងពីប្រតិបត្តិការទាំងនេះ ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ២៦ នៃរបាយការណ៍ហិរញ្ញវត្ថុ។

**ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាល មានភារកិច្ចធ្វើការបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង បង្ហាញនូវទិដ្ឋភាពពិត និង ត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលនៃប្រតិបត្តិអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) អនុវត្តគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យបានជាប់លាប់

(ខ) អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាននៃ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម ហៅកាត់ថា ("ស.រ.ហ.អ.ក.ស.ធ.ត.ម") និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬ ប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនេះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានសមរម្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដែលអាចប៉ាន់ស្មានបាន និង

(ង) ត្រួតពិនិត្យ និងដឹកនាំ ក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តជាសារវន្ត ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាសេចក្តីសម្រេចចិត្ត និង/ឬ សេចក្តីណែនាំទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមនូវរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយរណ៍ហិរញ្ញវត្ថុ។

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០

៤

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ពីថល ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)**
សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី ៩ ដល់ ៣៨ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ ។

ចុះហត្ថលេខាតាងនាមឱ្យក្រុមប្រឹក្សាភិបាល

លោក តាន់ ថាភត្រា
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥

Tel: +855 23 218 128
Fax: +855 23 993 225
www.bdo.com.kh

Suite 28 Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia



## របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជី៖ ០០០០៤៩៩០)

## សេចក្តីរាយការណ៍លើសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភី អិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ រួមទាំងគោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានបង្ហាញចាប់ពីទំព័រទី ៩ ដល់ ៣៨។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់មកជាមួយនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

### មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក")។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដានេះ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ *ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

*ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌*

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយ ស្របតាម *ក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យភាពអន្តរជាតិ)* ("ក្រមសីលធម៌ IESBA") របស់ក្រុមប្រឹក្សាស្តង់ដាសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើង ដោយអនុលោមតាមតម្រូវការនៃក្រមសីលធម៌ទាំងនេះ និងក្រមសីលធម៌ IESBA។

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមត: ខាប់ភីថល ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខចុះបញ្ជី៖ ០០០០៤៩៩០) (ត)**

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មខាងលើ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលមានក្នុងរបាយ-ការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍សវនកម្មខាងលើរបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនរួមបញ្ចូលព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនផ្តល់ទម្រង់សន្និដ្ឋានជាបែបធានាណាមួយឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអាននូវព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗមានភាពមិនសមស្របជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីសវនកម្ម ឬបើមិនដូច្នោះទេ លេចឡើងមានកំហុសឆ្គងជាសារវន្ត។

ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗ យើងខ្ញុំតម្រូវឱ្យរាយការណ៍នូវហេតុការណ៍ទាំងនោះ។ យើងខ្ញុំពុំមានអ្វីដើម្បីរាយការណ៍ក្នុងករណីនេះទេ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសត្រូវក្នុងការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗដែលក្រុមប្រឹក្សាភិបាលកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្រុមហ៊ុនឱ្យជៀសផុតពីកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវក្នុងការ វាយតម្លៃទៅលើលទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយធ្វើការបង្ហាញប្រសិនបើមានកត្តាដែលពាក់ព័ន្ធនឹងនិរន្តភាពនៃដំណើរការអាជីវកម្ម ហើយប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែបនិរន្តរភាព លុះត្រាតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយ ប៉ុន្តែត្រូវតែធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺទទួលបានអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុក្រុមហ៊ុនពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍របស់សវនករឯករាជ្យ ដែលមានការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែមិនអាចធានាថាការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែរកឃើញនូវកំហុសឆ្គងជាសារវន្តពេលដែលវាកើតមានឡើងនោះទេ។ កំហុសឆ្គងអាចកើតឡើងពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានចាត់ទុកជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្គុំ អាចមានឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់លើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខចុះបញ្ជី៖ ០០០០៤៩៩០) (ត)**

**ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)**

ជាផ្នែកមួយនៃសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តការវិនិច្ឆ័យដោយវិជ្ជាជីវៈ និងរក្សាបាននូវការសង្ស័យដោយវិជ្ជាជីវៈនៅក្នុងសវនកម្មទាំងមូល។ យើងខ្ញុំក៏បាន៖

- កំណត់ និងការវាយតម្លៃហានិភ័យកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាតើវាបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ហើយធ្វើការរៀបចំ និងអនុវត្តតាមនីតិវិធីសវនកម្មអាចឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់នូវមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាង ហានិភ័យដែលបណ្តាលមកពីការភ័ន្តច្រឡំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬក៏ការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ពន្ធទៅនឹងការធ្វើសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបញ្ចេញមតិយោបល់ពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះឡើយ។
- វាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានអនុវត្ត និងភាពសមហេតុផលនៃ ប៉ាន់ស្មានគណនេយ្យ និងលាតត្រដាងដែលពាក់ព័ន្ធ ដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល។
- ធ្វើសេចក្តីសន្និដ្ឋានលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ដែលប្រើប្រាស់ដោយគណៈគ្រប់គ្រង និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាកើតឡើងជាសារវន្ត ដែលពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចប៉ះពាល់ដល់លទ្ធភាពបន្តប្រតិបត្តិការរបស់ខ្លួនដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនមានច្បាស់លាស់ជាសារវន្តកើតឡើង យើងខ្ញុំត្រូវបានទាមទារការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្ម និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏កែប្រែមតិយោបល់របស់យើងខ្ញុំ ប្រសិនបើការកំណត់ទាំងនោះមិនគ្រប់គ្រាន់។ សេចក្តីសន្និដ្ឋានយើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន រហូតដល់ថ្ងៃចេញរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចនឹងបង្កឱ្យក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពនៃដំណើរការអាជីវកម្ម។
- វាយតម្លៃលើបទបង្ហាញ រចនាសម្ព័ន្ធ និងមាតិកា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមទាំងការលាតត្រដាង ថាតើរបាយការណ៍ហិរញ្ញវត្ថុក្រុមហ៊ុនតំណាងឱ្យប្រតិបត្តិការនិងព្រឹត្តិការណ៍ផ្សេងៗក្នុងរបៀបរបបមួយដែលសម្រេចបាននូវការបង្ហាញត្រឹមត្រូវ។

ក្នុងចំណោមចំណុចពាក់ព័ន្ធផ្សេងៗ យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាលអំពីផែនការទំហំការងារ និងពេលវេលានៃសវនកម្ម និងចំណុចសំខាន់ៗដែលបានរកឃើញ រួមមានទាំងកង្វះខាតក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងយើងខ្ញុំបានរកឃើញនៅក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

BDO



**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមត: ខាប់ភីថល ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខចុះបញ្ជី៖ ០០០០៤៩៩០) (ត)**

**បញ្ហាផ្សេងៗ**

របាយការណ៍នេះត្រូវបានធ្វើឡើងជូនចំពោះតែភាគហ៊ុនិករបស់ក្រុមហ៊ុនប៉ុណ្ណោះ។ យើងមិនទទួលខុសត្រូវចំពោះបុគ្គលផ្សេងណាម្នាក់ចំពោះខ្លឹមសារនៃរបាយការណ៍នេះទេ។

**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០



## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**

| | កំណត់សម្គាល់ | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ៤៥.៤៣៤ | ១៨២.៨៧២ | ៤០.១០០ | ១៦៣.៨០៩ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ៧៩.៧៩៥ | ៣២១.១៧៥ | ៧៨.៨២៦ | ៣២២.០០៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ១០៦.១០១ | ៤២៧.០៥៧ | ១៤៩.០១៤ | ៦០៨.៧២២ |
| ឥណទានទៅអតិថិជន | ៩ | ៤.១១២.៩២១ | ១៦.៥៥៤.៥០៧ | ៤.៣៦៨.៩៤៤ | ១៧.៨៤៧.១៣៦ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ២១.៨៦២ | ៨៧.៩៩៥ | ១៩.៨៣២ | ៨១.០១៤ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ១១.៨៨៤ | ៤៧.៨៣៣ | ២៦.៩៦៩ | ១១០.១៦៨ |
| ទ្រព្យអរូបី | ១២ | ៩៥៤ | ៣.៨៤០ | ២.០៩៩ | ៨.៥៧៤ |
| ទ្រព្យសកម្មពន្ធពន្យារ | ១៣ | ១៨.០០៨ | ៧២.៤៨២ | ១៨.០០៨ | ៧៣.៥៦៣ |
| **ទ្រព្យសកម្មសរុប** | | ៤.៣៩៦.៩៥៩ | ១៧.៦៩៧.៧៦១ | ៤.៧០៣.៧៩២ | ១៩.២១៤.៩៩០ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| កម្ចី | ១៤ | ២.១៨៥.៥២៨ | ៨.៧៩៦.៧៥០ | ២.៣២៨.៥៩៦ | ៩.៥១២.៣១៥ |
| គណនីត្រូវបង់ផ្សេងៗ | ១៥ | ៦៣.៥០១ | ២៥៥.៥៩៤ | ៦៥.១៣៤ | ២៦៦.០៧២ |
| បំណុលពន្ធចរន្ត | | ៤៤៧ | ១.៧៩៩ | ៤.០២៧ | ១៦.៤៥០ |
| **បំណុលសរុប** | | ២.២៤៩.៤៧៦ | ៩.០៥៤.១៤៣ | ២.៣៩៧.៧៥៧ | ៩.៧៩៤.៨៣៧ |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | ១.៥០០.០០០ | ៦.០០០.០០០ | ១.៥០០.០០០ | ៦.០០០.០០០ |
| ទុនបម្រុងតាមច្បាប់ | ១៧ | - | - | ១០.៦២៣ | ៤៣.១៨១ |
| ចំណេញរក្សាទុក | | ៦៤៧.៤៨៣ | ២.៦៤០.០៥២ | ៧៩៥.៤១២ | ៣.២៤២.៣៣៦ |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | ៣.៥៦៦ | - | ១៣៤.៦៣៦ |
| **មូលធនសរុប** | | ២.១៤៧.៤៨៣ | ៨.៦៤៣.៦១៨ | ២.៣០៦.០៣៥ | ៩.៤២០.១៥៣ |
| **បំណុល និងមូលធនសរុប** | | ៤.៣៩៦.៩៥៩ | ១៧.៦៩៧.៧៦១ | ៤.៧០៣.៧៩២ | ១៩.២១៤.៩៩០ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០



**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍ចំណូលពេញលេញ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**

| | កំណត់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១៨ | ៦៧៩.៥២១ | ២.៧៦៦.៣៣០ | ៧២៤.៣៥៣ | ២.៩៧៧.០៩១ |
| ចំណាយការប្រាក់ | ១៩ | (១៨១.១២៦) | (៧៣៧.៣៦៤) | (១៩៩.១០៨) | (៨១៨.៣៣៤) |
| ចំណូលការប្រាក់សុទ្ធ | | ៤៩៨.៣៩៥ | ២.០២៨.៩៦៦ | ៥២៥.២៤៥ | ២.១៥៨.៧៥៧ |
| សំវិធានធនសម្រាប់បំណុលជាប់សង្ស័យ | ៩ | (៨០.២៦៣) | (៣២៦.៧៥១) | (១១៦) | (៤៧៧) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២០ | ២៤២.២៤៩ | ៩៨៦.១៩៦ | ២៦៣.៨៧៣ | ១.០៨៤.៥១៨ |
| ចំណាយបុគ្គលិក | ២១ | (៥៦៥.៤២៤) | (២.៣០១.៨៤១) | (៥៣៨.៨៣៥) | (២.២១៤.៦១១) |
| ចំណាយរំលស់ | ២២ | (១៧.៩៨៩) | (៧៣.២៣៣) | (១៨.០៦៥) | (៧៤.២៤៧) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៣ | (២២៦.៤១៩) | (៩២១.៧៥២) | (២១១.០០២) | (៨៦៧.២១៨) |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (១៤៩.៤៥១) | (៦០៨.៤១៥) | ២១.១០០ | ៨៦.៧២២ |
| ចំណាយពន្ធ | ២៤ | (៩.១០១) | (៣៧.០៥០) | (៩.៨៤៤) | (៤០.៤៥៩) |
| (ខាត)/ចំណេញសម្រាប់ការិយបរិច្ឆេទ | | (១៥៨.៥៥២) | (៦៤៥.៤៦៥) | ១១.២៥៦ | ៤៦.២៦៣ |
| ចំណូលពេញលេញផ្សេងៗ សុទ្ធនៃពន្ធ | | | | | |
| ខ្ទង់គណនីដែលមិនបានបែងចែកឡើងវិញលើចំណេញ ឬខាត៖ | | | | | |
| - ការបកប្រែរូបិយប័ណ្ណបរទេស | | - | (១៣១.០៧០) | - | (៧៣.៧១៤) |
| (ខាត)/ចំណូលពេញលេញសរុបក្នុងការិយបរិច្ឆេទ | | (១៥៨.៥៥២) | (៧៧៦.៥៣៥) | ១១.២៥៦ | (២៧.៤៥១) |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០

១១

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមត: ខាប់គីថល ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | ដើមទុន | | ទុនបម្រុងតាមច្បាប់ | | ចំណេញរក្សាទុក | | លម្អៀងនៃការបកប្រែរូបិយប័ណ្ណបរទេស | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | **១.៥០០.០០០** | **៦.០០០.០០០** | **២០.៨៨២** | **៨៥.៣៤៥** | **៧៧៣.៨៩៧** | **៣.១៥៣.៩០៩** | **-** | **២០៨.៣៥០** | **២.២៩៤.៧៧៩** | **៩.៤៤៧.៦០៤** |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | ១១.២៥៦ | ៤៦.២៦៣ | - | - | ១១.២៥៦ | ៤៦.២៦៣ |
| លម្អៀងនៃការបកប្រែរូបិយប័ណ្ណបរទេស | - | - | - | - | - | - | - | (៧៣.៧១៤) | - | (៧៣.៧១៤) |
| ចំណូលពេញលេញសរុប | - | - | - | - | ១១.២៥៦ | ៤៦.២៦៣ | - | (៧៣.៧១៤) | ១១.២៥៦ | (២៧.៤៥១) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | | | | |
| ការផ្ទេរពីទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការសរុបជាមួយភាគហ៊ុនិក | - | - | (១០.២៥៩) | (៤២.១៦៤) | ១០.២៥៩ | ៤២.១៦៤ | - | - | - | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **១.៥០០.០០០** | **៦.០០០.០០០** | **១០.៦២៣** | **៤៣.១៨១** | **៧៩៥.៤១២** | **៣.២៤២.៣៣៦** | **-** | **១៣៤.៦៣៦** | **២.៣០៦.០៣៥** | **៩.៤២០.១៥៣** |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | (១៥៨.៥៥២) | (៦៤៥.៤៦៥) | - | - | (១៥៨.៥៥២) | (៦៤៥.៤៦៥) |
| លម្អៀងនៃការបកប្រែរូបិយប័ណ្ណបរទេស | - | - | - | - | - | - | - | (១៣១.០៧០) | - | (១៣១.០៧០) |
| ខាតពេញលេញផ្សេងៗសរុប | - | - | - | - | (១៥៨.៥៥២) | (៦៤៥.៤៦៥) | - | (១៣១.០៧០) | (១៥៨.៥៥២) | (៧៧៦.៥៣៥) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | | | | |
| ការផ្ទេរពីទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការសរុបជាមួយភាគហ៊ុនិក | - | - | (១០.៦២៣) | (៤៣.១៨១) | ១០.៦២៣ | ៤៣.១៨១ | - | - | - | - |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | **១.៥០០.០០០** | **៦.០០០.០០០** | **-** | **-** | **៦៤៧.៤៨៣** | **២.៦៤០.០៥២** | **-** | **៣.៥៦៦** | **២.១៤៧.៤៨៣** | **៨.៦៤៣.៦១៨** |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០



**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍លំហូរសាច់ប្រាក់**
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (១៤៩.៤៥១) | (៦០៨.៤១៥) | ២១.១០០ | ៨៦.៧២២ |
| និយ័តកម្ម៖ | | | | | |
| សំវិធានធនសម្រាប់បំណុលជាប់សង្ស័យ | ៩ | ៨០.២៦៣ | ៣២៦.៧៥១ | ១១៦ | ៤៧៧ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ១៦.៨៤៤ | ៦៨.៥៧២ | ១៧.៨៧៤ | ៧៣.៤៦២ |
| រំលស់ទ្រព្យអរូបី | ១២ | ១.១៤៥ | ៤.៦៦១ | ១៩១ | ៧៨៥ |
| ការជម្រះបញ្ជីនៃបំណុលពិបាកទារ | | ៤៨.៣៥៥ | ១៩៦.៨៥៣ | ២៧.២៨១ | ១១២.១២៥ |
| ចំណាយការប្រាក់ | ១៩ | ១៨១.១២៦ | ៧៣៧.៣៦៤ | ១៩៩.១០៨ | ៨១៨.៣៣៤ |
| ចំណេញប្រតិបត្តិការមុនពេលបម្រែបម្រួលដើមទុនបង្វិល | | ១៧៨.២៨២ | ៧២៥.៧៨៦ | ២៦៥.៦៧០ | ១.០៩១.៩០៥ |
| បម្រែបម្រួលដើមទុនបង្វិល | | | | | |
| ឥណទានទៅអតិថិជន | | ១២៧.៤០៥ | ៥១៨.៦៦៦ | (៦.១២៨) | (២៥.១៨៧) |
| គណនីត្រូវទទួលផ្សេងៗ | | (២.០២៩) | (៨.២៦០) | ២.៧៥៩ | ១១.៣៣៩ |
| គណនីត្រូវបង់ផ្សេងៗ | | (១.៦៣៤) | (៦.៦៥២) | (១៨៤.៦២២) | (៧៥៨.៧៩៨) |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | | ៣០២.០២៤ | ១.២២៩.៥៤០ | ៧៧.៦៧៩ | ៣១៩.២៥៩ |
| ពន្ធប្រាក់ចំណូលដែលបានបង់ | | (១២.៦៨១) | (៥១.៦២៤) | (៩.៨៧១) | (៤០.៥៧០) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ២៨៩.៣៤៣ | ១.១៧៧.៩១៦ | ៦៧.៨០៨ | ២៧៨.៦៨៩ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | (១.៧៥៩) | (៧.១៦១) | - | - |
| ការទិញទ្រព្យអរូបី | ១២ | - | - | (២.២៩០) | (៩.៤១២) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (១.៧៥៩) | (៧.១៦១) | (២.២៩០) | (៩.៤១២) |

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៤៩៩០



**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អមតៈ ខាប់ភីថល ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍លំហូរសាច់ប្រាក់**
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ (ត)

| | កំណត់សម្គាល់ | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីកម្ចី | | - | - | ៣.០៧២.៩៨២ | ១២.៦២៩.៩៥៨ |
| ការបង់សងកម្ចី | | (១៣៩.៦២២) | (៥៦៨.៤០១) | (២.៨៥២.៣១៧) | (១១.៧២៣.០២១) |
| ការប្រាក់បានបង់ | | (១៨៤.៥៧២) | (៧៥១.៣៩៣) | (១៨៤.៥៤៩) | (៧៥៨.៤៩៨) |
| សាច់ប្រាក់សុទ្ធបាន(ប្រើក្នុង)/បានមកពី សកម្មភាពហិរញ្ញប្បទាន | | (៣២៤.១៩៤) | (១.៣១៩.៧៩៤) | ៣៦.១១៦ | ១៤៨.៤៣៩ |
| **(តំហយ)/កំណើនសុទ្ធនៃសាច់ប្រាក់ និង សាច់ប្រាក់សមមូល** | | (៣៦.៦១០) | (១៤៩.០៣៩) | ១០១.៦៣៤ | ៤១៧.៧១៦ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើម ការិយបរិច្ឆេទ** | | ១៩២.៩៤០ | ៦៥៩.៨៤៥ | ៩១.៣០៦ | ៦៥៩.៨៤៥ |
| លម្អៀងនៃការបកប្រែរូបិយប័ណ្ណបរទេស | | - | ១១៨.៤២៣ | - | (២៨៩.៤០១) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុង ការិយបរិច្ឆេទ** | | ១៥៦.៣៣០ | ៦២៩.២២៩ | ១៩២.៩៤០ | ៧៨៨.១៦០ |

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | កំណត់សម្គាល់ | ២០២៤ ដុល្លារអាមេរិក | ២០២៤ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល |
|---|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៦ | ៤៥.៤៣៤ | ១៨២.៨៧២ | ៤០.១០០ | ១៦៣.៨០៩ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (មិនរួមបញ្ចូលប្រាក់តម្កល់តាមច្បាប់) | ៧ | ៤.៧៩៥ | ១៩.៣០០ | ៣.៨២៦ | ១៥.៦២៩ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ១០៦.១០១ | ៤២៧.០៥៧ | ១៤៩.០១៤ | ៦០៨.៧២២ |
| | | ១៥៦.៣៣០ | ៦២៩.២២៩ | ១៩២.៩៤០ | ៧៨៨.១៦០ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។*

២០២៤

របាយការណ៍
ប្រចាំឆ្នាំ ២០២៤

# ទីតាំងសាខា

## សាខាមុនីវង្ស

អាសយដ្ឋាន: ៥០២ C&D មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
លេខទូរសព្ទ: (855) 96-499-69-73 । (855) 99-337-377 । (855) 88-888-9773
អ៊ីម៉ែល: info@amatak.com.kh

## សាខាពោធិ៍សែនជ័យ

អាសយដ្ឋាន: ផ្ទះលេខ២៥A មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ
លេខទូរសព្ទ: (855) 10-666-210 । (855) 96-499-69-73
អ៊ីម៉ែល: info@amatak.com.kh

## សាខាទួលគោក

អាសយដ្ឋាន: ផ្ទះលេខA១៦៨ ផ្លូវលេខ២៨៩ ភូមិភូមិ៨ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ភ្នំពេញ
លេខទូរសព្ទ: (855) 15-283-212 । (855) 99-337-377
អ៊ីម៉ែល: info@amatak.com.kh